# ថ្នាំពុលការពារដំណាំ និងបញ្ហារបស់វា

## សៀវភៅសំរាប់កសិករ និងអ្នកផ្សព្វផ្សាយកសិកម្ម



យ៉ង សាំង កុមារ និង ឡាង សេងហ៊ង

ថ្នាំពុលការពារដំណាំ និង បញ្ហារបស់វា :

សៀវភៅសំរាប់កសិករ និង អ្នកផ្សព្វផ្សាយកសិកម្ម

និពន្ធដោយ : យ៉ង សាំង កុមារ និង ឡាង សេងហ៊ង

Yang Saing Koma and Lang Seng Horng

បោះពុម្ពលើកទី ១ នៅឆ្នាំ ២០០០ ចំនួន ៥០០០ ច្បាប់

© CEDAC 2000

ម.ព.ឯ.ក AIDOC
Code: 165-013
Date:
Donated by:

# ថ្នាំពុលការពារដំណាំ និងបញ្ហារបស់វា

ដោយ ៖ យ៉ឹង សាំង កុមារ និង ឡាង សេងហ៊ីង
មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CEDAC)

ឧបត្ថម្ភដោយអង្គការ OXFAM-AMERICA
ឆ្នាំ ២០០០

# សេចក្ដីថ្លែងអំណរគុណ


សៀវភៅនេះ ត្រូវបានបោះពុម្ពផ្សាយដោយ មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (អង្គការសេដាក CEDAC) ដែលជាអង្គការខ្មែរ បង្កើតឡើងដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍន៍កសិកម្មជាលក្ខណៈគ្រួសារនៅកម្ពុជា ។

ក្រៅពីអ្នកនិពន្ធ អ្នកដែលបានចូលរួមចំណែកសំខាន់ៗ ក្នុងការរៀបចំនិពន្ធសៀវភៅនេះមាន លោក គាម មករាឌី (ការអង្កេតប្រភេទថ្នាំពុលដែលបានលក់នៅលើទីផ្សារនៅកម្ពុជា) និងលោក លី ប៊ុនថៃ (ការសិក្សាករណីពុលមួយចំនួន) ។ រូបភាពនៅក្នុងកូនសៀវភៅនេះ ត្រូវបានគូរដោយ វិចិត្រករ ឱ យុទ្ធា ។ រូបភាពមួយចំនួនធំជាគំនិតរបស់អ្នកនិពន្ធ តែមានរូបភាពខ្លះ យើងបានដកស្រង់យកពីឯកសារផ្សេងៗ ដែលមានរាយនៅក្នុងឯកសារយោង ។

ក្រុមអ្នកនិពន្ធ ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបុគ្គលិកមជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍សិកម្មកម្ពុជាទាំងអស់ ដែលបានជួយផ្ដល់យោបល់កែលំអ ទាំងខ្លឹមសារ និងរូបភាព ជាពិសេស លោក ឃឹម សុផាណ្ណា បានជួយកែសំរួលផ្នែកខាងភាសា ។

យើងខ្ញុំ ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកសិករទាំងអស់ ដែលបានផ្ដល់រឿងពិតផ្ទាល់ខ្លួនសំរាប់ធ្វើការចុះផ្សាយ ។

មួយវិញទៀត កូនសៀវភៅនេះពិតជាពុំអាចលេចជារូបរាងឡើយបានទេ ប្រសិនបើពុំមានការជួយឧបត្ថម្ភថវិកាពីសំណាក់អង្គការអុកស្វាមអាមេរិក (Oxfam-America) ដែលយើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ។

# មាតិកាអត្ថបទ


❖ សេចក្តីថ្លែងអំណរគុណ

❖ សេចក្តីផ្តើម ........................................................................................................ ១

ជំពូកទី ១ ៖ ចំណេះដឹងជាមូលដ្ឋានទាក់ទងទៅនឹងថ្នាំពុលការពារដំណាំ

១.១. អ្វីទៅជាថ្នាំពុលការពារដំណាំ ?.................................................................. ២

១.២. តើ ថ្នាំពុលការពារដំណាំអាចធ្វើអោយមនុស្ស និងសត្វគ្រោះថ្នាក់ដូចម្តេច ?.......................... ៤

១.៣. ហេតុអ្វី បានជាមានថ្នាំពុលច្រើនមុខលក់នៅលើទីផ្សារ ?........................................... ៦

១.៤. តើ ភាពពុល និងគ្រោះថ្នាក់របស់ថ្នាំខុសគ្នាយ៉ាងដូចម្តេច.?........................................ ៨

១.៥. ហេតុអ្វី បានជាយើងគួរប្រើ ឬមិនគួរប្រើថ្នាំពុលការពារដំណាំ ?................................១១

ក. ហេតុអ្វី បានជាយើងគួរប្រើថ្នាំពុលការពារដំណាំ ?........................................១១

ខ. ហេតុអ្វី បានជាយើងមិនគួរប្រើថ្នាំពុលការពារដំណាំ ?....................................១២

ជំពូកទី ២ ៖ ថ្នាំពុលការពារដំណាំ និងភាពគ្រោះថ្នាក់

២.១. ថ្នាំពុល និងសុខភាពរបស់យើង........................................................................ ១៤

២.២. ថ្នាំពុល និងបរិស្ថាន ................................................................................... ២៣

ក. ភាពកខ្វក់ដល់ទឹក.............................................................................២៣

ខ. ភាពគ្រោះថ្នាក់ដល់សត្វមានប្រយោជន៍ផ្សេងៗ .............................................. ២៦

គ. ភាពសាំរបស់កត្តាចង្រៃ..................................................................... ២៩

ឃ. ការបន្សល់ទុកនូវជាតិថ្នាំក្នុងបរិស្ថាន.................................................... ៣០

២.៣. ថ្នាំពុល និងបញ្ហាដែលកើតមានឡើងក្នុងសហគមន៍............................................... ៣៣

២.៤. ថ្នាំពុល និងស្ថេរភាពនៃមុខរបរចិញ្ចឹមជីវិត ....................................................... ៣៥

ក. ការកើនឡើងនៃការចំណាយ............................................................... ៣៥

ខ. ការប៉ះពាល់ដល់សុខភាពអ្នកបរិភោគបន្លែ ................................................... ៣៦

គ. ការបាត់បង់កំលាំងពលកម្ម និងការចំណាយលើការថែរក្សាសុខភាព ........................ ៣៧

ជំពូកទី ៣ : ការកាត់បន្ថយភាពគ្រោះថ្នាក់របស់ថ្នាំពុលដល់សុខភាព និងបរិស្ថាន សំណូមពរទុងក្រោយ...................................................... ៥៦

ឧបសម្ព័ន្ធ : បញ្ជីរាយឈ្មោះថ្នាំដែលជៀសវាងប្រើ ឬប្រើដោយប្រុងប្រយត្ន័បំផុត

តារាងទី ១ : ថ្នាំពុលដែលពុលខ្លាំងបំផុតដល់មនុស្ស ...................................... ៥៧

តារាងទី ២ : ប្រភេទថ្នាំពុលដែលពុលខ្លាំងបំផុតដល់ត្រី...................................... ៦០

តារាងទី ៣ : ប្រភេទថ្នាំពុលដែលពុលខ្លាំងដល់ឃ្មុំ ...................................... ៦២

តារាងទី ៤ : ប្រភេទថ្នាំពុលដែលស្ថិតនៅក្នុងបរិស្ថានរយៈពេលយូរ ...................... ៦៤

តារាងទី ៥ : បញ្ជីថ្នាំពុលការពារដំណាំមាននៅខេត្តកណ្តាល កំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង សៀមរាប និងកំពង់ធំ...................................... ៦៦

# សេចក្តីផ្តើម

## ១. ហេតុអ្វី បានជាយើងរៀបរៀងសរសេរកូនសៀវភៅនេះឡើង ?

មានកសិករខ្មែរជាច្រើន ជាពិសេសអ្នកប្រកបមុខរបរដាំន្លៃ និងដំណាំផ្សេងៗ សំរាប់លក់ ក៏ដូចជាអ្នកធ្វើស្រែប្រាំងបាន និងកំពុងនិយមប្រើថ្នាំពុលដែលទិញពីទីផ្សារ ។ កសិករយើងមួយចំនួនធំ ចាត់ទុកថ្នាំពុលជាដំណោះស្រាយមួយលឿន ស្រួលទាន់ចិត្តក្នុងការការពារដំណាំ ។ មានកសិករខ្លះយល់ថា ថ្នាំពុលជាថ្នាំដែលជួយអោយដំណាំលូតលាស់បានល្អ ។ កសិករភាគច្រើនដែលយើងជួប បានប្រើប្រាស់ថ្នាំដោយមិនដឹងថាវាជាថ្នាំត្រូវនឹងសត្វល្អិត ឬជំងឺអ្វីនោះទេ ពេលខ្លះគាត់មិនដឹងថាវាជាថ្នាំប្រភេទអ្វីអោយច្បាស់លាស់ ដោយចេះតែប្រើស្មានៗ លាយច្រើនមុខចូលគ្នា លាយគ្មានកំរិតច្បាស់លាស់ និងបាញ់ច្រើនសា ។ នៅពេលប្រើប្រាស់ គេហាក់ដូចជាមិនសូវមានការបារម្ភអំពីសុខភាពផ្ទាល់ខ្លួនទាល់តែសោះ ។ មានកសិករខ្លះមិនបានកត់សំគាល់ថា ខ្លួនធ្លាប់ប្រើថ្នាំ រហូតដល់ពេលធ្លាក់ខ្លួនឈឺធ្ងន់ទើបយល់ថាមកពីការប្រើថ្នាំច្រើនជ្រុលពេក ។ មានអ្នកខ្លះដាំបន្លែយូរទៅសឹងតែរកប្រាក់ចំណូលមកទប់នឹងការចំណាយលើការប្រើថ្នាំ និងព្យាបាលជម្ងឺផ្ទាល់ខ្លួនសឹងមិនបាន រហូតដល់ផ្អាក ឬ បោះបង់មុខរបរនេះចោល ។ មានអ្នកខ្លះបាញ់ខ្លួនឯងលែងកើត ក៏ជួលអ្នកដទៃមកបាញ់ រហូតដល់អ្នកស៊ីឈ្នួលបាញ់ថ្នាំអោយគេនោះ បាញ់លែងកើត ដោយខ្លួនឯងធ្លាក់ខ្លួនឈឺដែរ ។ល។

បញ្ហាទាក់ទងការយល់ច្រឡំ ឬ ការខ្វះខាតនូវការយល់ដឹងពីថ្នាំពុល និងបញ្ហារបស់វានេះ នាំមកនូវផលវិបាកយ៉ាងច្រើនដល់អ្នកបរិភោគ បរិស្ថាន និងសង្គមមនុស្សទាំងមូល ។ ដោយមានការបារម្ភលើបញ្ហាទាំងនេះ ទើបយើងខ្ញុំរៀបចំជាកូនសៀវភៅនេះឡើង ដើម្បីចូលរួមចំណែកក្នុងការបង្កើននូវភាពភ្ញាក់រឭក និងយល់ដឹងអំពីថ្នាំពុល និងបញ្ហារបស់វា ។ យើងខ្ញុំសង្ឃឹមថាកូនសៀវភៅនេះ អាចជាជំនួយមួយយ៉ាងសំខាន់សំរាប់កសិករខ្មែរយើងក្នុងការអនុវត្តន៏ការការពារដំណាំមួយដែលប៉ះពាល់ដល់សុខភាព និងបរិស្ថានក្នុងកំរិតទាបបំផុត ។ យើងសូមបញ្ជាក់ថា ក្រៅពីសៀវភៅនេះ យើងនឹងចេញផ្សាយកូនសៀវភៅមួយទៀត ដែលស្តីអំពីវិធានការដាំដំណាំដោយមិនអាស្រ័យនឹងថ្នាំពុលគីមី ។

## ២. តើ សៀវភៅនេះមានខ្លឹមសារអ្វីខ្លះ ?

សៀវភៅនេះបែងចែកជា ៣ ជំពូកធំៗគឺ :

នៅជំពូកទី ១ យើងធ្វើការបកស្រាយពន្យល់អំពីពតិមានជាមូលដ្ឋានទាក់ទងទៅនឹងថ្នាំការពារដំណាំ ។ នៅជំពូកទី ២ យើងធ្វើការបង្ហាញអំពីថ្នាំការពារដំណាំ និងភាពគ្រោះថ្នាក់របស់វា ។ ក្រោយពេលអានចប់ អ្នកអាចនឹងបានទទួលពតិមានសំខាន់ៗ ដូចជា :

- ឥទ្ធិពលរបស់ថ្នាំពុលទៅលើសុខភាព
- ថ្នាំពុល និងបញ្ហាទាក់ទងទៅនឹងបរិស្ថាន
- ថ្នាំពុល និងបញ្ហាដែលកើតមានឡើងទាក់ទងនឹងទំនាក់ទំនងនៅក្នុងសហគមន៍
- ថ្នាំពុល និងឥទ្ធិពលរបស់វាទៅលើមុខរបរចិញ្ចឹមជីវិតរបស់កសិករ

នៅជំពូកទី ៣ យើងបានរាយនូវវិធានការណែនាំខ្លះ សំរាប់កសិករយកទៅអនុវត្តក្នុងករណីដែលគេត្រូវតែប្រើថ្នាំដោយខានមិនបាន ។ វិធានការទាំងនេះ អាចជួយអោយកសិករកាត់បន្ថយនូវគ្រោះថ្នាក់របស់ថ្នាំពុលដល់សុខភាព ។

ផ្ទួបផ្សំជាមួយអត្ថបទ យើងបានបញ្ចូលរូបភាពជាច្រើន ដើម្បីអោយខ្លឹមសាររបស់កូនសៀវភៅនេះកាន់តែងាយយល់ថែមទៀត ។

នៅក្នុងអត្ថបទ យើងតែងតែណែនាំអោយអ្នកអានប្រើប្រាស់តារាងដែលមាននៅក្នុងឧបសម្ព័ន្ធ (តារាងដែលភ្ជាប់នៅផ្នែកខាងក្រោយរបស់សៀវភៅ) ។ យើងមានរៀបចំតារាងចំនួន ៥ ដែលតារាងទាំងនោះគ្រាន់តែជំនួយដល់បងប្អូន ជាពិសេសក្នុងការសំរេចចិត្តទិញថ្នាំណាមួយមកប្រើ ។ ថ្នាំដែលមានរាយនៅក្នុងតារាងនេះសុទ្ធសឹងតែថ្នាំមានលក់នៅតាមទីផ្សារនៅប្រទេសកម្ពុជា ។ តារាងដែលមាននៅក្នុងឧបសម្ព័ន្ធមាន :

- តារាងរាយឈ្មោះថ្នាំពុល ដែលពុលខ្លាំងដល់មនុស្ស( ថ្នាំដែលមិនត្រូវប្រើ)
- ប្រភេទថ្នាំពុល ដែលពុលខ្លាំងបំផុតដល់ត្រី
- ប្រភេទថ្នាំពុល ដែលពុលខ្លាំងដល់ឃ្មុំ
- ប្រភេទថ្នាំពុល ដែលស្ថិតនៅក្នុងបរិស្ថានរយៈពេលយូរ
- បញ្ជីរាយឈ្មោះថ្នាំពុល ដែលមាននៅខេត្តកណ្តាល កំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង សៀមរាប និងកំពង់ធំ

អ្នកនិពន្ធទទួលស្គាល់ថា បងប្អូនកសិករច្បាស់ជាមានការលំបាកក្នុងការប្រើតារាងនេះ ។ ដូចនេះ យើងសុំសំណូមពរ អោយបងប្អូនកសិករពិគ្រោះយោបល់ជាមួយអ្នកបច្ចេកទេសកសិកម្មនៅតាមតំបន់ ឬអ្នកដែលមានការរៀនសូត្របានច្រើន ជាពិសេសគ្រូបង្រៀនតាមភូមិ ។

## ជំពូកទី ១ : ចំណេះដឹងជាមូលដ្ឋានទាក់ទងទៅនឹងថ្នាំពុលការពារដំណាំ

បន្ទាប់ពីអ្នកអានចប់នូវជំពូកទី ១ នេះ អ្នកនឹងអាចឆ្លើយនូវសំនួរសំខាន់ៗ ដូចខាងក្រោមនេះ :

- តើអ្វីទៅ ជាថ្នាំពុលការពារដំណាំ ? ហើយថ្នាំពុលការពារដំណាំចែកជាប៉ុន្មានប្រភេទ ?
- តើ ថ្នាំពុលការពារដំណាំអាចធ្វើអោយមនុស្ស និងសត្វពុលតាមរបៀបណាខ្លះ ?
- តើ ថ្នាំពុលការពារដំណាំមានកំរិតពុលខុសគ្នាយ៉ាងណាខ្លះ ?
- តើហេតុអ្វី បានជាមានថ្នាំច្រើនមុខលក់នៅលើទីផ្សារ ?
- តើ ការប្រើថ្នាំពុលការពារដំណាំ នាំមកនូវគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះ ?

# ជំពូកទី ១ : ចំណេះដឹងជាមូលដ្ឋានទាក់ទងទៅនឹងថ្នាំពុលការពារដំណាំ

## ១.១. អ្វីទៅជាថ្នាំពុលការពារដំណាំ ?

ថ្នាំពុលការពារដំណាំ គឺជាថ្នាំដែលប្រើប្រាស់សំរាប់សំលាប់ ឬបណ្តេញ*កត្តាចង្រៃ* របស់ដំណាំ និងកសិផល ។ កត្តាចង្រៃមានដូចជា ដង្កូវប្រភេទផ្សេងៗ ចៃ កណ្តុរ មេរោគផ្សិត បាក់តេរី ។ល។ ដោយសារយើងច្រើនប្រើវាសំរាប់ការពារដំណាំ និងកសិផលផ្សេងៗ ទៀត ពីការបំផ្លាញដោយកត្តាចង្រៃ *យើងក៏អាចហៅវាថាថ្នាំការពារដំណាំបានដែរ* ។ គេសង្កេតឃើញថា ខ្មែរយើងបានហៅឈ្មោះខុសៗ គ្នា ដូចជា *ថ្នាំពុល ថ្នាំពុលគីមី ថ្នាំគីមីកសិកម្ម ឬថ្នាំកសិកម្ម* ។ នៅក្នុងកូនសៀវភៅនេះ យើងប្រើពាក្យ *ថ្នាំពុលការពារដំណាំ* ជាពាក្យដែលមានន័យដូចថ្នាំពុល ហើយជាផ្នែកមួយនៃថ្នាំកសិកម្ម ។

យោងទៅតាមប្រភេទកត្តាចង្រៃដែលបំផ្លាញដំណាំ គេអាចចែកថ្នាំការពារដំណាំជាច្រើនប្រភេទ ដូចខាងក្រោមនេះ :

- ថ្នាំសំលាប់បាណកសត្វ ឬសត្វល្អិត ( ឧទាហរណ៏ មេអំបៅ និងដង្កូវផ្សេងៗ)
- ថ្នាំសំលាប់ចៃ និងសង្កើច
- ថ្នាំសំលាប់ដង្កូវសំប៉ែត ឬដង្កូវណេម៉ាតូត
- ថ្នាំសំលាប់ពពួកខ្យង
- ថ្នាំសំលាប់ពពួកទំពារ ( ឧទាហរណ៏ កណ្តុរ)
- ថ្នាំសំលាប់រុក្ខជាតិ ( ថ្នាំសំលាប់ស្មៅ)
- ថ្នាំសំលាប់មេរោគផ្សិត ។ល។

ដើម្បីអោយដឹងច្បាស់ថា ថ្នាំណាវាសំលាប់អ្វី សូមលោកអ្នកមើលតារាងទី ៥ នៅទំព័រទី ៦៦ ។




**រូបភាពទី ១: ថ្នាំពុលការពារដំណាំសំខាន់ៗ ដែលមានលក់លើទីផ្សារ**

នៅលើទីផ្សារ គេសង្កេតឃើញមានថ្នាំច្រើនប្រភេទ និងច្រើនមុខណាស់ តែថ្នាំដែលសំបូរជាងគេគឺពពួកថ្នាំ សម្លាប់បាណកសត្វ ឬថ្នាំសំលាប់សត្វល្អិត ។

## ១.២. តើ ថ្នាំការពារដំណាំអាចធ្វើអោយមនុស្ស និងសត្វគ្រោះថ្នាក់តាមរបៀបណាខ្លះ ?

គ្មានថ្នាំការពារដំណាំណា ដែលអត់ពុលដល់មនុស្ស និងសត្វទេ (គោ ក្របី ជ្រូក មាន់ ទា ត្រី ។ល។) គ្រាន់តែកំរិតពុល របស់វាខុសៗ គ្នាប៉ុណ្ណោះ ។

ថ្នាំពុល អាចចូលក្នុងរាងកាយរបស់យើងតាម ៣ របៀប (សូមមើលរូបភាពទី ២ និង ទី ៣) :

- តាមរយៈការលេបចូល ឬតាមមាត់
- ជ្រាបចូលតាមរយៈស្បែក (តាមរន្ធស្បែក)
- ចូលតាមរយៈការដកដង្ហើម

រូបភាពទី ២: ថ្នាំពុលអាចចូលមកក្នុងខ្លួនមនុស្សតាមមាត់ និងការដកដង្ហើម



រូបទីភាព ៣ : ថ្នាំពុលអាចចូលទៅក្នុងខ្លួនមនុស្សយើងតាមមាត់ និងរន្ធស្បែក



ការចូលតាមមាត់ កើតឡើងជាពិសេសនៅពេលយើងហូបចំណី ពិសារបារី ដោយមិនបានលាងដៃ ដែលប្រឡាក់ជាតិថ្នាំ ឬតាមរយៈការហូបបន្លែមានជាតិថ្នាំពុលនៅប្រឡាក់ជាប់នៅឡើយ ។

ចំណែកការពុលតាមរយៈស្បែក គឺកើតឡើងនៅពេលដែលយើងបាញ់ថ្នាំ ដោយមិនបានស្លៀកពាក់ការពារ នាំអោយទឹកថ្នាំប្រឡាក់ជាប់ខ្លួន ឬខោអាវរបស់យើងដាច ឬជូនកាលយើងប្រើដៃទទេលាយថ្នាំ ។ល។

**ឧទាហរណ៍** ៈ មានបុរសម្នាក់រស់នៅភូមិសន្ទុកក្នុង ឃុំក្រកោះ ស្រុកសន្ទុក បានយកថ្នាំពុលមកលាបខ្លួនរបស់គាត់ ដើម្បីការពារកុំអោយសត្វអង្រួងខាំ ពេលគាត់ឡើងដើមស្វាយ ។ គ្រាន់តែលាបខ្លួនមិនទាន់ហើយស្រួលបួលផង គាត់ក៏ទន់ខ្លួនដួលតែម្តង ។

ការពុលតាមរយៈការដកដង្ហើម គឺកើតមានឡើងជាពិសេសនៅពេលដែលយើងបាញ់ថ្នាំដែលមានក្លិនខ្លាំង មិនបានពាក់ម៉ាសរុំមុខ ឬក៏ចូលមកកន្លែងដែលទើបបាញ់ថ្នាំហើយ ។

ដូចនេះ សូមលោកអ្នកកុំយល់ច្រឡំថា ថ្នាំពុលគឺពុលតែនៅពេលយើងផឹក ឬលេបវាប៉ុណ្ណោះ ។ តាមពិតការជ្រាបចូលតាមរន្ធស្បែក និងការដកដង្ហើមក៏អាចបណ្តាលអោយមានគ្រោះថ្នាក់ដូចគ្នាដែរ ។

## ១.៣. ហេតុអ្វី បានជាមានថ្នាំពុលច្រើនមុខលក់នៅលើទីផ្សារ ?

ថ្នាំការពារដំណាំ ដែលមានដាក់លក់នៅលើទីផ្សារ ជាផលិតផលបានមកពីការផ្សំឡើងនូវ *ធាតុសកម្ម និង ធាតុបន្សំ ឬធាតុបន្ថែម* ។ ធាតុសកម្ម ជាធាតុពុលពិតប្រាកដរបស់ថ្នាំ ។ ដូចនេះ ក្នុងចំណោមថ្នាំដែលអស់លោកអ្នកទិញយកមកប្រើពីផ្សារ គ្មានថ្នាំណាមួយដែលមានធាតុសកម្ម ១០០ ភាគរយទេ ។

ចំណែកឯធាតុផ្សំ ឬធាតុបន្ថែម ជាធាតុមួយដែលបំពេញតួនាទីផ្សេងៗ ដូចជា ៈ

- សំរាប់ជួយធាតុសកម្មងាយរលាយក្នុងទឹក
- ជួយអោយធាតុសកម្មបន្សាប ហើយរលាយសព្វល្អពេលលាយថ្នាំបាញ់
- ជួយអោយដំណក់ថ្នាំបែកសាយភាយលើស្លឹកបន្តិចម្តងៗ ពេលបាញ់ហើយ
- ជួយអោយម្សៅថ្នាំរលាយក្នុងទឹកសព្វបានល្អ
- ជួយអោយថ្នាំស្អិតជាប់នៅលើស្លឹក ពេលបាញ់ហើយ
- ជួយអោយអំពើរបស់សារធាតុសកម្មកាន់តែខ្លាំងឡើង ។ល។

តាមពិតធាតុបន្សំក៏មានជាតិពុលខ្លះៗ ដែរ គ្រាន់តែកំរិតពុលរបស់វាខ្សោយជាងធាតុសកម្ម ។ ដោយសារថ្នាំផ្សំឡើងដោយធាតុសកម្មផ្សេងៗ និងផ្សំឡើងដោយក្រុមហ៊ុនផ្សេងៗ បានជានៅលើទីផ្សារ យើងឃើញមានថ្នាំពុលដាក់លក់ក្រោមផ្លាកឈ្មោះ ឬយីហោផ្សេងៗ គ្នា ។ ផ្លាកឈ្មោះថ្នាំ ឬយីហោថ្នាំផ្សេងៗ ដែលមាននៅលើដប ឬកញ្ចប់ថ្នាំ អ្នកបច្ចេកទេសហៅថា *ឈ្មោះពាណិជ្ជកម្ម* ។

តាមលទ្ធផលនៃការសិក្សារបស់យើងនៅឆ្នាំ ២០០០ នៅលើទីផ្សារក្នុងបណ្តាខេត្តជាប់បឹងទន្លេសាប មានថ្នាំរហូតដល់ ២៤១ មុខ ដែលមានឈ្មោះពាណិជ្ជកម្មខុសៗ គ្នា ។ ក៏ប៉ុន្តែ ក្នុងចំណោមថ្នាំដែលមានផ្លាកឈ្មោះពាណិជ្ជកម្មខុសៗ គ្នា ក៏មានថ្នាំខ្លះផ្សំឡើងដោយធាតុសកម្មតែមួយដែរ ។

**ឧទាហរណ៍ :** ហ្វូសឌ្រីន (ផ្ទិត) សូឌ្រីន ហ្វីទ័រ (បាតដៃ) ជាថ្នាំដែលមានផ្លាកសញ្ញាឈ្មោះខុសគ្នា តែតាមពិតវាផ្សំឡើងដោយធាតុសកម្មតែមួយដែលមានឈ្មោះហៅថា *មេវ៉ាំងហ្វូស* ។

ក្នុងករណីនេះ អ្នកបច្ចេកទេសគេសន្មតដាក់ *ឈ្មោះរួម* មួយអោយពពួកថ្នាំ ដែលមានឈ្មោះពាណិជ្ជកម្មខុសៗ គ្នា តែផ្សំឡើងដោយធាតុសកម្មតែមួយ ។ ដូចនេះ បើគិតតាមឈ្មោះរួម ថ្នាំដែលមានលក់នៅលើទីផ្សារក្នុងបណ្តាខេត្តជាប់បឹងទន្លេសាប មានតែ ៧៨ មុខទេ ។ នៅលើពិភពលោកយើងនេះ មកទល់ចុងឆ្នាំ ១៩៩៩ គេរាយការណ៍ថា មានថ្នាំពុលចំនួន ១០៤៤ មុខ ដែលមានឈ្មោះរួមផ្សេងៗ គ្នា ។

ដូចនេះ នៅពេលយើងទិញថ្នាំមកប្រើ សូមពិនិត្យមើលអោយមែនទែន ពីព្រោះថ្នាំខ្លះមានផ្លាកឈ្មោះពាណិជ្ជកម្មខុសៗ គ្នាមែន តែមានសារធាតុសកម្មដូចគ្នា ឬឈ្មោះរួមតែមួយទេ ។ ដោយថ្នាំការពារដំណាំមានច្រើនប្រភេទ នៅពេលយើងទិញថ្នាំសំរាប់យកមកប្រើក្នុងករណីចាំបាច់ យើងត្រូវស្វែងយល់អោយបានច្បាស់ជាមុនសិន តើដំណាំយើងជួបបញ្ហាអ្វី ? ហើយថ្នាំប្រភេទណាដែលអាចយកមកប្រើបាន ?

ដើម្បីងាយស្រួលក្នុងការជ្រើសរើស យើងបានធ្វើជាបញ្ជីមួយ ដែលបែងចែកថ្នាំទៅតាមកត្តាចង្រៃ កំរិតនៃភាពពុល ឬភាពគ្រោះថ្នាក់របស់វា ដល់មនុស្ស សត្វ និងបរិស្ថាន ក៏ដូចជា ឈ្មោះរួម និងឈ្មោះពាណិជ្ជកម្មរបស់វា ។ បញ្ជីឈ្មោះថ្នាំការពារដំណាំ មាននៅទំព័រ ៥៨ ដល់ទំព័រ ៧៧ ។ ប្រសិនបើ លោកអ្នកមិនច្បាស់លើប្រភេទថ្នាំដែលត្រូវប្រើ សូមទំនាក់ទំនងជាមួយមន្ត្រីកសិកម្ម ឬអ្នកផ្សព្វផ្សាយកសិកម្មដែលនៅបំរើការតាមមូលដ្ឋាន ។

**រូបទី ៤ : មុនសំរេចចិត្តទិញថ្នាំអ្វីមួយ អ្នកត្រូវប្រមូលពត៌មានអោយបានគ្រប់គ្រាន់**




## ១.៤. តើ ភាពពុល និងភាពគ្រោះថ្នាក់របស់ថ្នាំខុសគ្នាយ៉ាងដូចម្តេច ?

អង្គការសុខភាពពិភពលោក (WHO) បានធ្វើចំណាត់ថ្នាក់ថ្នាំពុលជា ៤ ក្រុម ដោយយោងទៅតាមភាពពុលរបស់វា ។ ក្រុមទាំង ៤ នេះមាន :

- ក្រុមគ្រោះថ្នាក់ខ្លាំងមែនទែន ( ក្រុមលេខ ១.ក)
- ក្រុមគ្រោះថ្នាក់ខ្លាំង ( ក្រុមលេខ ១.ខ)
- ក្រុមគ្រោះថ្នាក់ខ្លាំងល្មម ( ក្រុមលេខ ២)
- ក្រុមមិនសូវគ្រោះថ្នាក់ ( ក្រុមលេខ ៣)

ដើម្បីងាយស្រួលយល់ថា តើ កំរិតពុល ឬ កំរិតគ្រោះថ្នាក់របស់ក្រុមនិមួយៗ ខុសគ្នាយ៉ាងណា យើងសូមធ្វើការបកស្រាយដូចខាងក្រោមនេះ

| | |
|---|---|
| ក្រុមគ្រោះថ្នាក់ខ្លាំងមែនទែន (តាងដោយក្រុមលេខ ១.ក) | មានន័យថា បរិមាណថ្នាំតែ ២ ទៅ ៣ ដំណក់ ដល់ ១ កូនស្លាបព្រា អាចធ្វើអោយមនុស្សពេញជំទង់ម្នាក់ ពុលស្លាប់ |
| ក្រុមគ្រោះថ្នាក់ខ្លាំង (តាងដោយក្រុមលេខ ១.ខ) | មានន័យថា ជាតិពុលពី ១ កូនស្លាបព្រា ដល់ ២ ស្លាបព្រាបាយ អាចធ្វើអោយមនុស្សពេញវ័យម្នាក់ពុលស្លាប់បាន |
| ក្រុមគ្រោះថ្នាក់ខ្លាំងល្មម (តាងដោយក្រុមលេខ ២) | មានន័យថា ជាតិពុលមានបរិមាណពី ២ ស្លាបព្រាបាយ ដល់ ១កូនកែវ ទើបអាចពុលស្លាប់មនុស្សពេញវ័យម្នាក់បាន |
| ក្រុមមិនសូវគ្រោះថ្នាក់ តាងដោយក្រុមលេខ ៣ | មាននយ័ថា ជាតិពុលមានបរិមាណពី ២ កូនកែវ ដល់ ១ កែវ (ប្រហែលកន្លះលីត្រ) ទើបអាចសំលាប់មនុស្សពេញវយ័ម្នាក់បាន |

ដើម្បីអោយងាយយល់បានច្បាស់ល្អថែមទៀតលើការបែងចែកកំរិតគ្រោះថ្នាក់ សូមលោក-អ្នក ប្រៀបធៀបជាមួយ រូបភាពទី ៥ ។

យើងខ្ញុំក៏សូមបញ្ជាក់ផងដែរថា កំរិតគ្រោះថ្នាក់នេះ គឺគ្រាន់តែបង្ហាញពីភាពពុល ឬគ្រោះថ្នាក់ភ្លាមៗប៉ុណ្ណោះ តែវាមិនបានបញ្ជាក់ពីភាពពុល ឬគ្រោះថ្នាក់យូរអង្វែង ឬពុលរ៉ាំរ៉ៃទេ (សូមអានបន្ថែមនៅទំព័រនៅទំព័រទី ១៤ ដល់ ២២) ។

### រូបភាពទី ៥ : ការប្រៀបធៀបកំរិតពុល ឬគ្រោះថ្នាក់របស់ថ្នាំពុលការពារដំណាំ



ដូចនេះ នៅពេលលោកអ្នកទិញថ្នាំពុលមកប្រើ ឬយកមកលក់បន្ត យកល្អជៀសវាងទិញថ្នាំពុលនៅក្រុមទី ១.ក និង ១.ខ ។ ណាមួយទៀត ពពួកថ្នាំដែលស្ថិតនៅក្រុមទី ១.ក និង ១.ខ គឺស្ថិតនៅក្នុងការហាមឃាត់របស់រដ្ឋ ។ ប្រសិនបើលោកអ្នកចង់ដឹងថា ពពួកថ្នាំណានៅក្រុមណាសូមអានតារាងឈ្មោះថ្នាំនៅទំព័រ ៦៦ ដល់ ៧៧ ។

នៅពេលអ្នកប្រើថ្នាំពុលសូមអ្នកគិតថា សុខភាពរបស់អ្នក និងគ្រួសារអ្នក វាមានតម្លៃជាងប្រាក់ចំណេញដែលបានទទួលពីការប្រមូលផលលើសរាប់ពាន់ដង ។

## ១.៥. ហេតុអ្វី បានជាយើងគួរប្រើ ឬមិនគួរប្រើថ្នាំការពារដំណាំ ?

ការរីកចំរើននៃវិទ្យាសាស្ត្រ ធ្វើអោយមនុស្សអាចបង្កើតបាននូវថ្នាំការពារដំណាំផ្សំឡើងដោយធាតុគីមីដែលមានប្រសិទ្ធិភាពខ្ពស់។ ក៏ប៉ុន្តែគួរអោយស្តាយ ថ្នាំការពារដំណាំក៏នាំមកនូវបញ្ហា ឬផលវិបាកមួយចំនួនដែរ។ ហេតុដូចនេះ បានជាមានការខ្វែងគំនិតគ្នា ដោយក្រុមម្ខាងយល់ឃើញថា ការប្រើប្រាស់ថ្នាំការពារដំណាំ អាចនាំផលប្រយោជន៍មកយ៉ាងច្រើន តែក្រុមម្ខាងទៀតយល់ឃើញថា ថ្នាំការពារដំណាំនាំមកនូវបញ្ហាច្រើនជាងដំណោះស្រាយ ។ ទាក់ទងនឹងបញ្ហានេះ យើងខ្ញុំសូមលើកយកមកនូវអំណះអំណាងផ្សេងៗ មកបង្ហាញ :

### ក). ហេតុអ្វី បានជាយើងគួរប្រើថ្នាំការពារដំណាំ ?

ក្រុមដែលគាំទ្រការប្រើប្រាស់ថ្នាំការពារដំណាំមានអំណះអំណាងដូចខាងក្រោម :

- ជាទូទៅ ថ្នាំពុលការពារដំណាំជាមធ្យោបាយមួយដែលមានប្រសិទ្ធិភាព អាចឱ្យយើងទុកចិត្តបាន ហើយអាចឈ្នះ លើកត្តាចង្រៃផ្សេងៗ ជាច្រើន
- ថ្នាំគីមី មានប្រសិទ្ធិភាពលឿនទាន់ចិត្ត ហើយអាចកាត់បន្ថយ ឬទប់ស្កាត់ការបំផ្លាញដំណាំ ជាលក្ខណៈធ្ងន់ធ្ងរ បានក្នុងពេលយ៉ាងខ្លី ហើយពេលខ្លះវាជាមធ្យោបាយតែមួយគត់ នៅពេលដែលការបំផ្លាញមានភាពធ្ងន់ធ្ងរ
- ការប្រើថ្នាំពុលការពារដំណាំ អាចអនុវត្តបានគ្រប់ទីកន្លែង ដោយវាមិនប្រកាន់តំបន់ រដូវកាល ផ្ទៃដីធំ ឬផ្ទៃដីតូចឡើយ
- ថ្នាំគីមីបច្ចុប្បន្ន មានលក់នៅសឹងគ្រប់ទីកន្លែង ងាយស្រួលរកទិញ ងាយដឹកជញ្ជូន ហើយជួនកាល វាស្ថិតនៅក្នុងកំរិតតំលៃមួយថោកល្មម ដែលកសិករភាគច្រើន អាចមានប្រាក់ទិញបាន

- ការប្រើថ្នាំពុលការពារដំណាំ ងាយស្រួល ដោយបរិមាណថ្នាំដែលត្រូវប្រើមានចំនួនតិច ហើយត្រូវការពេលតិច សំរាប់បាញ់
- ការប្រើថ្នាំពុលការពារដំណាំជាបច្ចេកវិទ្យាមួយទំនើបជឿនលឿនទាន់សម័យ
- ផលិតផលដែលបាញ់ថ្នាំមានរូបរាងល្អ ដែលធ្វើឱ្យអ្នកប្រើប្រាស់មួយចំនួនចូលចិត្តទិញ

## ខ). ហេតុអ្វី បានជាយើងមិនគួរប្រើថ្នាំពុលការពារដំណាំ ?

ក្រុមដែលយល់ថាកសិករគួរចៀសវាងការប្រើថ្នាំពុលដើម្បីការពារដំណាំ មានអំណះអំណាងដូចខាងក្រោមនេះ:

- ថ្នាំពុល វាមិនត្រឹមតែសម្លាប់កត្តាចង្រៃរបស់ដំណាំទេ គឺវាថែមទាំងសំលាប់សត្វមានប្រយោជន៍ផ្សេងៗ ទៀត
- គ្មានថ្នាំណាមួយ ដែលមិនពុលដល់មនុស្ស និងសត្វស្រុកទេ គ្រាន់តែកំរិតពុលរបស់វាខុសៗ គ្នា ប៉ុណ្ណោះ
- គ្មានថ្នាំណាមួយ អាចការពារការបំផ្លាញបាន ១០០% ទេ
- គ្មានថ្នាំណាមួយ ដែលមិនបន្សល់ទុកនូវជាតិពុលក្នុងដំណាំ ដី ទឹកទេ គ្រាន់តែរយះពេលនៃការរលាយ ឬបន្សាប របស់វាខុសគ្នា
- ការប្រើថ្នាំការពារដំណាំយូរទៅបណ្តាលសត្វមានការកើនឡើងនូវ<u>*ភាពស៊ាំ*</u> នៃថ្នាំ និង<u>*ភាពញៀន*</u> នៃការប្រើថ្នាំ
- គ្មានថ្នាំណាមួយ ដែលយើងមិនត្រូវចំណាយប្រាក់ដើម្បីទិញទេ ហើយការចំណាយ កើននូវបន្ទុកដល់កសិករ

ជាសរុបមក គេយល់ឃើញថាការប្រើថ្នាំពុលអាចនាំមកនូវបញ្ហាជាច្រើនដល់សុខភាពអ្នកប្រើ និងអ្នកបរិភោគ ដល់បរិស្ថាន ដល់មុខរបរចិញ្ចឹមជីវិត និងដល់ទំនាក់ទំនងក្នុងសហគមន៍ ។ ហើយបញ្ហានេះ អាចកើតមានឡើងកាន់តែធ្ងន់ធ្ងរប្រសិនបើកសិករយើងប្រើប្រាស់ និងទុកដាក់ថ្នាំពុលខុសរបៀប ឬមិនអនុវត្តន៍តាមគោលការណ៍បច្ចេកទេស ( សូមមើលរូបទី ៦ បន្ថែម) ។

នៅប្រទេសកម្ពុជា យើងសង្កេតឃើញថា កសិករភាគច្រើនប្រើប្រាស់ថ្នាំពុលដោយខ្វះខាតការយល់ដឹងពីរបៀបប្រើ និងផលវិបាករបស់វា ។ កសិករភាគច្រើនប្រើថ្នាំហួសកំរិត លាយថ្នាំច្រើនមុខពេកចូលគ្នា ប្រើថ្នាំដោយមិនដឹងប្រភេទថ្នាំច្បាស់លាស់ ប្រើប្រាស់ដោយគ្មានការពារខ្លួនបានស្រួលបួល ទុកថ្នាំ និងសំបកថ្នាំដោយធ្វេសប្រហែស ។ល។ ដោយសារការអនុវត្តទាំងនេះ វាអាចនាំមកនូវបញ្ហាជាច្រើនដល់សុខភាពអ្នកប្រើ អ្នកបរិភោគ ដល់បរិស្ថាន និងបញ្ហាផ្សេងៗ ទៀតក្នុងសង្គម ។ ហេតុនេះហើយ បានជាយើងលើកយកនូវបញ្ហារបស់ថ្នាំពុលមកបកស្រាយនៅជំពូកបន្តបន្ទាប់ ដើម្បីបង្កើននូវការយល់ដឹង និងការភ្ញាក់រលឹករបស់កសិករលើបញ្ហាដ៏សំខាន់នេះ ។

**រូបភាពទី ៦ : បញ្ហាផ្សេងៗ ដែលកើតមានឡើងដោយសារការប្រើ និងការទុកដាក់ថ្នាំពុលខុសរបៀប**



# ជំពូកទី ២ : ថ្នាំការពាររុក្ខជាតិ និងគ្រោះថ្នាក់របស់វា

បន្ទាប់ពីអ្នកសិក្សាជំពូកទី២ នេះចប់ អ្នកនឹងបានយល់ច្បាស់អំពីគ្រោះថ្នាក់របស់ថ្នាំពុលដូចជា :

- ថ្នាំពុល និងបញ្ហាសុខភាព
- ថ្នាំពុល និងបញ្ហាបរិស្ថាន
- ថ្នាំពុល និងឥទ្ធិពលរបស់វាលើសហគមន៍
- ថ្នាំពុល និងឥទ្ធិពលរបស់វាលើមុខរបរចិញ្ចឹមជីវិតរបស់កសិករ

## ២.១. ថ្នាំពុល និងសុខភាពរបស់យើង

ដូចយើងបានដឹងរួចហើយ ថ្នាំពុលអាចប៉ះពាល់ដល់រាងកាយ និងសុខភាពរបស់យើងតាមរយៈការចូលតាមមាត់ តាមស្បែក និងការដកដង្ហើម ។ ថ្នាំពុលដែលចូលក្នុងខ្លួនមនុស្សយើង អាចបង្កអោយកើតមានរោគសញ្ញា និងសញ្ញាពុលមួយចំនួន ។ ក្នុងករណីពុលខ្លាំង ឬពុលភ្លាម រោគសញ្ញាលេចចេញក្រោយពេលថ្នាំពុលចូលក្នុងខ្លួនមនុស្សយើង ក្នុងពេលកន្លះម៉ោង ឬ មួយម៉ោង ហើយជាតិពុលអាចបាត់ទៅវិញក្នុងរយៈពេល ២ ទៅ ២៤ ម៉ោងដោយអាស្រ័យទៅតាមប្រភេទថ្នាំពុល ។ រោគសញ្ញា និងបំរែបំរួលមិនស្រួលក្នុងខ្លួន កើតមានឡើងដោយសារថ្នាំមានឥទ្ធិពលលើ ប្រព័ន្ធសសៃប្រសាទ លើសាច់ដុំ ទឹកក្រពេញ និងសរីរាង្គមួយចំនួនដូចជា ភ្នែក សួត ក្រពះ និងពោះវៀន ។

**ប្រអប់ទី១: រោគសញ្ញាសំខាន់ៗ និងបំរែបំរួលកើតមានឡើងក្នុងរាងកាយដោយសារឥទ្ធិពលថ្នាំពុល**

- ប្រព័ន្ធសសៃប្រសាទ: ឈឺក្បាល វិលមុខ ធ្មើយហត់ ប្រកាច់ ញ័រដៃ ដំណើរទ្រេតទ្រោត សន្លប់ ភ្លឹក
- សាច់ដុំ : រមួលក្រពើ សាច់ដុំខ្សោយ ញាក់ត្របកភ្នែក
- ទឹកក្រពេញ : បែកញើសច្រើន ចេញទឹកមាត់ច្រើន ចេញទឹកភ្នែកច្រើន
- សរីរាង្គផ្សេងៗ : ដកដង្ហើមថប់ៗ ក្អួត រាគ ឈឺទ្រូង ហៀរសំបោរ ក្អួត ឈឺពោះ ចង់ក្អួត ព្រិលភ្នែក

ដើម្បីងាយស្រួលយល់ យើងខ្ញុំបានពិពណ៌នារោគសញ្ញាសំខាន់ៗ ដែលអាចកើតមានឡើងដោយសារឥទ្ធិពលថ្នាំពុល តាមរយៈរូបភាពនៅទំព័រ ១៥ និង ១៦ ។

តាមរូបភាពទី ៩ កន្លែងនៅលើដងខ្លួនរបស់យើងអាចស្រូបយកថ្នាំពុលខ្លាំងជាងគេ គឺនៅត្រង់បរិវេណតំរងនោម ។ បន្ទាប់មកមានថ្ងាស គុម្ពត្រចៀក និងលលាដ៏ក្បាល ។ នៅត្រង់ចំនុចនេះ យើងគួរមានការប្រុងប្រយត្ន័ក្នុងការបាញ់ថ្នាំ ហើយត្រូវរកសំភារះការពារអោយបានជិតល្អ ។

## រូបភាពទី ៧: រោគសញ្ញាសំខាន់ៗ និងការប្រែប្រួលក្នុងរាងកាយ ដោយសារឥទ្ធិពលរបស់ថ្នាំពុល



ឈឺក្បាល



វិលមុខ



ចង់ក្អួត ឬខ្ពើមឆ្អើមខ្លាំង



ឈឺទ្រូង





ក្អួតចង្អោរ





រោលស្បែក

## រូបភាពទី ៨: រោគសញ្ញាសំខាន់ៗ និងបំរែបំរួលក្នុងរាងកាយដោយសារឥទ្ធិពលរបស់ថ្នាំពុល



ឈឺចាប់ ឬចុកសាច់ដុំ



ញើសខុសធម្មតា



រមួលសរសៃ




រាគរូស



ពិបាកដកដង្ហើម



ស្រវាំងភ្នែក



ស្លាប់

**រូបភាពទី ៩៖ កន្លែងនៅលើខ្លួនមនុស្សយើង ដែលងាយស្រូបចូលជាតិថ្នាំពុល**



រោគសញ្ញារបស់ថ្នាំពុលអាចខុសគ្នាខ្លះៗ ដែរ អាស្រ័យទៅតាមប្រភេទរបស់ថ្នាំជាពិសេស សារធាតុសកម្មរបស់ថ្នាំ (សូមអានឧទាហរណ៍នៅក្នុងប្រអប់ទី ២) ។

**ប្រអប់ទី២: ឧទាហរណ៍រោគសញ្ញាពុលរបស់ថ្នាំពុលមួយចំនួន**

◆ ថ្នាំពពួកម៉ូនីទរ័ (Monitor) ដែលកសិករយើងហៅថាទឹកស្អុយ ពេលវាចូលក្នុងខ្លួនមនុស្ស វាអាចបង្កអោយកើតរោគសញ្ញា និងសញ្ញាពុលភ្លាមៗ ដូចជា ញ័រទ្រូង ឈឺក្បាល ស្រវាំងភ្នែក ហៀរសំបោរ ចង់ក្អួត រាគ រមួលក្នុងពោះ ភ្លឹក បែកញើស និងសន្លប់ ។ រោគសញ្ញាពុលរ៉ាំរ៉ៃ វាអាចប៉ះពាល់ដល់សួតថ្លើម បេះដូង និងប្រព័ន្ធសរសៃប្រសាទ ។

◆ ថ្នាំម៉េវីនហ្វូស (Mevinphos) កសិករយើងហៅថារូបផ្តិត វាមានលក្ខណៈពុលភ្លាមៗ ដូចថ្នាំម៉ូនីទរ័ដែរ ហើយវាបង្កអោយមានរោគពុលរ៉ាំរ៉ៃលើប្រព័ន្ធសរសៃប្រសាទ ។

បញ្ហាគួរអោយព្រួយបារម្ភមួយដែរ គឺឥទ្ធិពលនៃថ្នាំពុលទៅលើការបង្កកំណើតរបស់មនុស្ស ។ តាមការស្រាវជ្រាវកន្លងមក គេបានធ្វើអំណះអំណាងថា ឥទ្ធិពលរបស់ថ្នាំពុលក៏អាចធ្វើអោយមានការប៉ះពាល់ដល់កូននៅក្នុងផ្ទៃ អាចបណ្តាលអោយកូនរលូត កើតមិនគ្រប់ខែ ឬក៏អាចធ្វើអោយមានការផ្លាស់ប្តូរដល់លក្ខណៈបន្តពូជ (ឧទាហរណ៍ វាអាចទៅជាគ្មានកូន) ។

**ប្រអប់ទី ៣: លទ្ធផលស្រាវជ្រាវ**

ក្រុមស្រាវជ្រាវមកពីមហាវិទ្យាល័យកសិកម្ម នៃប្រទេសហូឡង់បានធ្វើការសិក្សានៅឆ្នាំ ១៩៩១ ទៅលើគូស្វាមីភរិយាចំនួន ៨៦៣ គូ ដែលបុរសជាស្វាមីធ្លាប់ប៉ះពាល់ថ្នាំពុលសំលាប់សត្វល្អិត ។ តាមលទ្ធផលនេះបានបញ្ជាក់ថា សមត្ថភាពបង្កកំណើតរបស់បុរសមានលក្ខណៈខ្សោយ ។
(រស្មីកម្ពុជា ១៥/០៨/១៩៩៩)

**រូបភាពទី ១០៖ គ្រោះថ្នាក់ដែលអាចកើតមានឡើងដល់ស្ត្រី និងទារកក្នុងផ្ទៃ**





ផលវិបាកសំខាន់ដល់សុខភាព បន្ទាប់ពីប្រើថ្នាំពុលអស់រយៈពេលយូរឆ្នាំគឺ ការចុះទ្រុឌទ្រោម នៃសុខភាព និងរាងកាយដែលគេហៅថា ភាពពុលរ៉ាំរ៉ៃ ។ ភាពពុលរ៉ាំរ៉ៃនេះ កើតមានចំពោះអ្នកទទួលឥទ្ធិពល ពីថ្នាំពុលរយៈពេលរាប់ខែ រាប់ឆ្នាំមកហើយ ។

រោគសញ្ញា និងការបំរែបំរួលមិនល្អក្នុងរាងកាយដោយសារការពុលរ៉ាំរ៉ៃមានដូចជា :

- ការខ្សោយសាច់ដុំ មានន័យថាវាហាក់ដូចជាយើងចាប់អ្វីមួយចេះតែរបូតពីដៃ
- ដំណើរទ្រេតទ្រោត មានលក្ខណៈដូចជាមនុស្សស្រវឹងស្រា
- ញ័រដៃ ញ័រជើងជាប់រហូត
- មានកើតបញ្ហាលើស្បែក ដូចជាបែកស្រកា របកស្បែក កន្ទួលក្រហមជាដើម
- មានការភ្លេចភ្លាំង
- មានកើតរោគភ័យស្លន់ស្លោ និងមានពេលខ្លះអាចប្រកាច់
- ការរលាកក្រពះ តំរងនោម និងថ្លើម
- កំលាំងមានការចុះថយ

តែកន្លងមកមានបងប្អូនកសិករមួយចំនួនមិនជឿថា ការប្រើថ្នាំពុលដោយធ្វេសប្រហែសអាចនាំមកនូវរោគរ៉ាំរ៉ៃទេ ។ ដើម្បីអោយលោកអ្នកបានជ្រាបកាន់តែច្បាស់ តើរោគរ៉ាំរ៉ៃអាចកើតមានឡើងយ៉ាងណាខ្លះ យើងខ្ញុំសូម បង្ហាញនូវរឿងពិតមួយចំនួនដូចខាងក្រោមនេះ :

**ក). លោកអ៊ុំ ខឹន លាង** អាយុ ៦៤ ឆ្នាំ រស់នៅក្នុងភូមិទួលស្គី ឃុំតាលុន ស្រុកស្អាង ខេត្តកណ្តាល គាត់ធ្លាប់ប្រើថ្នាំពុល ២៥ ឆ្នាំ មកហើយ ។ ថ្នាំដែលគាត់ធ្លាប់ប្រើមាន ដេដេតេ អាស្សូឌ្រីន ហ្វូសឌ្រីន និង ហ្វូលីដូល ដែលកសិករហៅ ដេរ៉ា ។ គាត់ធ្លាប់ពុលក្នុងកំរិតធ្ងន់បង្គួរ ២-៣ ដង ក្នុងពេលបច្ចុប្បន្ននេះ គាត់ឈប់បាញ់ថ្នាំ ៣ ឆ្នាំ មកហើយ ។ រោគសញ្ញាដែលគាត់កើតមានជាង ១០ ឆ្នាំ នេះមាន:

- ការងឿងក្បាល តឹងទ្រូង រោយដៃជើង អស់កំលាំង និងស្រវាំងភ្នែក ដែលកើតឡើងមួយសប្តាហ៍ ៥ ដង ហើយពេលខ្លះ ជារៀងរាល់ថ្ងៃ
- បែកញើសស្អិត និងការអស់កំលាំងលេចចេញឡើងក្នុងរយៈពេល ១ ឆ្នាំម្តង ហើយវាកើតឡើងមិនថារដូវរងារ ឬក្តៅទេ

- ការកើតរមាស់សើរស្បែកនៅលើខ្លួន និងនៅលើជើងប្រមាណជា ១០ ឆ្នាំ ហើយតែវាមានលក្ខណៈ ជាមិនដាច់
- ការវង្វេងកើតមានឡើងមួយឆ្នាំម្តង ហាក់បីដូចជាគ្មានវិញ្ញាណនៅក្នុងខ្លួន មិនដឹងថាចង់ទៅកន្លែងណា

**ខ). ពូ អុល** អាយុ ៣៨ ឆ្នាំ ជាកសិករដាំបន្លែរស់នៅក្នុង ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល ។ គាត់ធ្លាប់ប្រើថ្នាំលើដំណាំបន្លែ ១៥ ទៅ ១៦ ឆ្នាំ មកហើយ និងក៏ជាអ្នកធ្លាប់ស៊ីឈ្នួលបាញ់ថ្នាំអោយគេទៀតផង ។ គាត់ធ្លាប់លាយថ្នាំបាញ់ពី ៣ ទៅ ៦ មុខចូលគ្នា ។ នៅពេលបាញ់ម្តងៗ គាត់មិនសូវមានអ្វីការពារអោយបានល្អទេ មានពេលខ្លះមានស្បែកពាក់ខោអាវខ្លី ។ បច្ចុប្បន្ននេះ គាត់ឈប់បាញ់ និងដាំបន្លែ ៣ ឆ្នាំ ហើយ ដោយមានឈឺជំងឺរ៉ាំរ៉ៃ ។ រោគសញ្ញាកើតមានចំពោះគាត់គឺៈ

- ការប៉ះពាល់ដល់គ្រឿងក្នុងមាន រលាកថ្លើម និងសួត និងការខ្សោយក្រលៀន
- ការចុះកំលាំង និងការហេវហត់ជាប្រចាំ

**គ). លោកពូ សៅ ខុន** រស់នៅភូមិក្នុងព្រែក ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល ជាកសិករដាំបន្លែតាំងពីឆ្នាំ ១៩៨៤ មកម្លេះ ។ គាត់ធ្លាប់លាយថ្នាំពី ៣ រហូតដល់ ៧ មុខចូលគ្នា ។ គាត់ក៏មិនសូវមានការប្រុងប្រយត្ន័អ្វីទេក្នុងពេលបាញ់ថ្នាំ ។ ក្នុងមួយថ្ងៃ គាត់បាញ់ថ្នាំពី ១៥ ទៅ ២០ ធុង និងធ្លាប់ពុលថ្នាំច្រើនលើកមកហើយ ក្នុងស្ថានភាពធ្ងន់ក៏មាន ស្រាលក៏មាន ។ រោគសញ្ញាពុលរ៉ាំរ៉ៃ ដែលគាត់មានបច្ចុប្បន្នគឺ :

- ការស្រវាំងភ្នែកកើតមានឡើងប្រមាណជាង ១០ ឆ្នាំ មកហើយ
- ការរសេះរសោះដៃជើង ឈឺចុកចាប់ពេញខ្លួន ដេកមិនស្រួល រមួលក្រពើ និងត្រជាក់ដៃជើង ដែលកើតមានឡើងជារៀងរាល់ពេលយប់
- ការថយចុះកំលាំងជាប្រចាំ

## រូបទី ១១: ភាពទ្រុឌទ្រោមនៃសុខភាព និងកម្លាំងពលកម្មតាមរយៈការប្រើប្រាស់ ថ្នាំពុលខុសរបៀប

ក. កសិករមិនសូវ មានការប្រុងប្រយ័ត្ន





ខ. ពេលបាញ់យូរទៅៗ ធ្វើអោយ កំលាំងគាត់មានការថយចុះ ហើយ ថែមទាំងអាចមានជំងឺរ៉ាំរ៉ៃទៀតផង

គ. ដំណាក់កាលចុងក្រោយ គាត់ មិនបន្ត ក្នុងការដាំដុះបាន ទៀតទេ ដោយបញ្ហាសុខភាព របស់គាត់ កាន់តែយ៉ាប់ទៅៗ តែបទពិសោធន៍ របស់គាត់ អាចជាមេរៀនសំរាប់ ក្មេងជំនាន់ក្រោយ



## ២.២. ថ្នាំពុល និងបរិស្ថាន

ការប្រើប្រាស់ថ្នាំពុល នាំមកនូវផលវិបាក ឬបញ្ហាបន្ទាប់បន្សំជាច្រើន ដែលមានឥទ្ធិពលមិនល្អដល់បរិស្ថាន ដូចជា នាំមកនូវភាពកខ្វក់ដល់ទឹក សំលាប់សត្វមានប្រយោជន៍ផ្សេងៗ បង្កឱ្យមានភាពស៊ាំទៅនឹងថ្នាំ និងការផ្ទុះឡើងនូវកត្តាចង្រៃ និងភាពបន្សល់ទុកនូវកាកសំណល់ថ្នាំក្នុងបរិស្ថានធម្មជាតិយូរអង្វែង ។

### ក. ភាពកខ្វក់ដល់ទឹក

នៅពេលយើងបាញ់ថ្នាំ បរិមាណថ្នាំយ៉ាងច្រើនមិនបានទៅនៅលើដំណាំទេ គឺវាធ្លាក់មកលើដី ។ នៅពេលធ្លាក់មកលើដី ជាតិថ្នាំជ្រាបចូលក្នុងដី ឬហូរចេញទៅកន្លែងផ្សេងៗ ដូចជា ថ្លុក ត្រពាំង ស្រះ ប្រឡាយ បឹង ស្ទឹង ទន្លេ ។ សូមបញ្ជាក់ផងដែរថា ថ្នាំពុលក៏អាចជ្រាបចូលដល់ទឹកក្នុងអណ្តូងបានដែរ ជាពិសេសប្រសិនបើ អណ្តូងនេះគ្មានលូការពារ ។

**ប្រអប់ទី ៤: រឿងពិត**

ឧទាហរណ៍ នៅសហរដ្ឋអាមេរិក បន្ទាប់ពីការប្រើថ្នាំពុលយូរឆ្នាំមក នៅឆ្នាំ ១៩៨៦ គេបានស្រាវជ្រាវឃើញថា ថ្នាំពុលចំនួន ១៩ ប្រភេទ មាននៅក្នុងទឹកក្រោមដី នៅក្នុងរដ្ឋចំនួន ២៤ ។ ដោយសារបញ្ហានេះ ទើបនៅកន្លែងខ្លះ គេមិនអាចបរិភោគទឹកនៅតំបន់គេបានទេ ទាល់តែនាំទឹកដបពីប្រភពផ្សេងៗ មកបរិភោគវិញ ។

នៅពេលយើងលាងធុងបាញ់ថ្នាំ និងចោលសំបកថ្នាំតាមមាត់ទឹក ក្នុងទឹក ពេលនោះជាតិថ្នាំពុល ក៏បង្កឱ្យមានភាពកខ្វក់ដល់ទឹក ។ ភាពកខ្វក់នៃទឹក ក៏ធ្វើឱ្យមនុស្ស និងសត្វពុលបានដែរ នៅពេលយើងផឹកវានោះ។ ប្រការដែលគ្រោះថ្នាក់បំផុត គឺកើតនៅពេលដែលយើងផឹកទឹកពីស្រែដែលបាញ់ថ្នាំហើយ ។ នេះជាករណីមួយដែល យើងធ្លាប់ជួបប្រទះនៅកម្ពុជាយើង ។ ភាពកខ្វក់នៃទឹក ដោយសារជាតិថ្នាំពុល វាក៏អាចបង្កគ្រោះថ្នាក់ដល់ ក្មេងៗ ដែលឃ្វាលគោតាមវាលតាមកាល ដោយជួនកាលក្មេងៗ ទាំងនោះផឹកទឹកតាមប្រឡាយស្រែ ត្រពាំង បឹង ។ល។

ត្រី ក្តាម ខ្យង និងសត្វដទៃទៀត ដែលរស់នៅក្នុងទឹក ក៏ពុលតាមរយៈភាពកខ្វក់នេះដែរ ។ ជាពិសេសសត្វទាំងនេះឆាប់ចាញ់ជាតិពុលណាស់ ។ ទឹកដែលមានជាតិថ្នាំពុលមិនសំលាប់មនុស្សមែន តែវាអាចពុលដល់សត្វទាំងនោះ ហើយជួនកាលយើងយកសត្វ ទាំងនេះមកហូបក៏បង្កអោយមានគ្រោះថ្នាក់ដល់យើងដែរ ។

**ប្រអប់ទី ៥ : ភាពគ្រោះថ្នាក់ដោយសារការបរិភោគត្រីក្នុងស្រែបាញ់ថ្នាំ**

◆ នៅដើមឆ្នាំ ១៩៧០ ប្រជាជនរាប់រយនាក់ នៅភូមិភាគខាងត្បូងប្រទេសឥណ្ឌា ជួបប្រទះនូវជំងឺចំឡែកម្យ៉ាង ដោយបង្កឱ្យមានភាពចុកចាប់ខ្លួនប្រាណ ប្រៀបដូចជាពិការរាងកាយ ។ បន្ទាប់ពីការស្រាវជ្រាវមក គេសន្និដ្ឋានថា នេះមកពីអ្នកទាំងនោះបរិភោគក្តាមដែលចាប់ពីវាលស្រែដែលបានបាញ់ថ្នាំពុល ។

◆ មានក្រុមគ្រួសារមួយនៅក្នុង ឃុំកោះខែល ស្រុកស្អាងខេត្តកណ្តាល បាននាំគ្នាទៅចាប់ក្តាមនៅស្រែដែលគេទើបតែប្រើថ្នាំ ហ្វុយរ៉ាដង់ (កសិករហៅថ្នាំបំពុលសត្វ) រយៈពេល ២ថ្ងៃ ដើម្បីយកមកបរិភោគ ។ ក្រោយពីហូបក្តាមហើយ សមាជិកក្នុងក្រុមគ្រួសារទាំងនោះឈឺពោះផង និងក្អួតផង ។

**រូបភាពទី ១២៖ ការយកធុងថ្នាំមកលាង និងការបោះបង់ចោលនូវសំបកដបថ្នាំក្នុងបឹង ស្ទឹង ទន្លេអាចនាំមកនូវភាពគ្រោះថ្នាក់ដល់សត្វ និងសុខភាពមនុស្ស**



នៅពេលប្រើប្រាស់ថ្នាំ សូមបងប្អូនប្រយ័ត្នប្រយែងកុំអោយជាតិថ្នាំហូរចូលមកត្រពាំង បឹង ស្ទឹង ទន្លេ ។ល។ ការបោះសំបកដបថ្នាំចោលក្នុងទឹកក៏ត្រូវតែចៀសវាងដែរ ។ ការប្រើថ្នាំក្បែរកន្លែងមានអណ្តូងទឹកក៏គួរចៀសវាងដែរ ។ម្យ៉ាងវិញទៀត ដាច់ខាតកុំបរិភោគទឹកពីវាលស្រែដែលបាញ់ថ្នាំ និងកុំហូបក្តាម ខ្យង ត្រីដែលងាប់ដោយសារឥទ្ធិពលថ្នាំពុលអោយសោះ ។

## ៩. ភាពគ្រោះថ្នាក់ដល់សត្វមានប្រយោជន៍ផ្សេងៗ ទៀត

នៅពេលយើងបាញ់ថ្នាំ ជាតិថ្នាំដែលនៅទើរលើរុក្ខជាតិ ដី និងក្នុងទឹក ក៏អាចពុលដល់សត្វផ្សេងៗ ទៀត ដែលយើងគ្មានបំណងសំលាប់ ។ សត្វដែលមានប្រយោជន៍សំខាន់មានដូចជា ពពួកពាំលំអងផ្កា (ឧទាហរណ៍ ឃ្មុំ) ។ ឃ្មុំ ជាសត្វមួយមានសារៈប្រយោជន៍ដល់ធម្មជាតិ និងមនុស្សយើងណាស់ ដោយវាជួយពាំនាំលំអងផ្កា ដើម្បីជួយដល់រុក្ខជាតិឱ្យបង្កាត់ មានផ្លែមានផល ។ ដូចនេះ ប្រសិនបើបរិមាណឃ្មុំត្រូវថយចុះ ឬបាត់បង់ ពេលនោះវាធ្វើឱ្យរុក្ខជាតិមួយចំនួនមិនសូវមានផ្លែផលបានល្អដូចធម្មតា ។ ម្យ៉ាងទៀត ឃ្មុំជាសត្វផលិតទឹកឃ្មុំសំរាប់ជាឱសថ និងអាហារយ៉ាងប្រសើររបស់មនុស្សផង ។

ដូចនេះ ពេលយើងបាញ់ថ្នាំ សូមគិតដល់សត្វឃ្មុំ និងសត្វពាំលំអងផ្សេងៗ ទៀតផង ហើយចៀសវាងកុំបាញ់ពេលដំណាំមានផ្កា និងកុំបាញ់ពេលព្រឹក និងថ្ងៃត្រង់ ។

មានសត្វមានប្រយោជន៍ផ្សេងៗ ទៀត ដែលគេហៅថា "*<u>មិត្តរបស់កសិករ</u>*" ដោយសារសត្វនោះវាជួយស៊ីសត្វដែលបំផ្លាញដំណាំរបស់យើង ។ មិត្តរបស់កសិករ មានដូចជា <u>ពីងពាង កន្ទុំរុយ កង្កែប ពស់ ចាប</u> ។ល។ មិត្តរបស់កសិករ ជួយធ្វើយ៉ាងណាឱ្យបរិមាណសត្វដែលបំផ្លាញដំណាំស្ថិតនៅក្នុងបរិមាណកំណត់មួយ ដោយពួកវាស៊ីសត្វដែលបំផ្លាញដំណាំ ។ ក៏ប៉ុន្តែ ពេលយើងបាញ់ថ្នាំខ្លាំងពេក វាក៏បណ្តាលឱ្យសត្វទាំងនោះងាប់ដែរ ។ នៅពេលសត្វដែលស៊ីសត្វ បំផ្លាញដំណាំថយចុះ ឬ បាត់បង់ ពេលនោះវាបង្កលក្ខណៈងាយស្រួលឱ្យពពួកសត្វបំផ្លាញដំណាំកើតកូន កើតចៅបានច្រើន ហើយបង្កបញ្ហាកាន់តែខ្លាំងដល់ដំណាំយើង ។ ពេលនោះសត្វដែលស៊ីដំណាំក្លាយជា "*<u>កញ្ចាចថ្មើ</u>*" មែនទែន ហើយ ។

រូបទី ១៣ : ក្នុងធម្មជាតិតែងតែមានសត្វមានប្រយោជន៍ស៊ីសត្វល្អិតដែលបំផ្លាញដំណាំ



**រូបទី ១៤: ការប្រើថ្នាំពុលអាចសម្លាប់សត្វមានប្រយោជន៍ផ្សេងៗ ទៀត**



នៅពេលយើងបាញ់ថ្នាំ វាក៏បណ្តាលអោយសត្វមានប្រយោជន៏ទាំងនោះងាប់ដែរ ។ នៅពេលដែលបរិមាណសត្វដែលស៊ីសត្វល្អិតបំផ្លាញដំណាំមានការថយចុះ ពេលនោះវាបង្កលក្ខណៈងាយស្រួលអោយពពួកសត្វបំផ្លាញដំណាំកកើតកូនចៅបានច្រើន ហើយបង្កអោយមានបញ្ហាកាន់តែច្រើនឡើងដល់ដំណាំ (បញ្ហាដែលយើងកំពង់ជួបប្រទះបច្ចុប្បន្ននេះ) ។ សភាពការណ៏របៀបនេះ វាអាចនាំអោយមានការលេចឡើងនូវការបំផ្លាញកាន់តែច្រើនឡើងៗ ដែលភាសាបច្ចេកទេស ហៅថា*ការផ្ទុះចេញកត្តាចង្រៃ* ។ ការផ្ទុះចេញនូវកត្តាចង្រៃនេះ វានាំអោយមានបញ្ហាកាន់តែច្រើនមកលើយើងថែមទៀត (សូមអានបន្ថែមនៅចំណុច គ ទំព័រ ២៩ ) ។ ក្រៅពីផលប៉ះពាល់ដល់ "*មិត្តរបស់កសិករ*" ការប្រើប្រាស់ថ្នាំពុលក៏អាចសំលាប់ ឬបន្ថយ សកម្មភាពដល់សត្វល្អិតដែលរស់នៅក្នុងដីដែរ ។ ឧទាហរណ៏ ជន្លេនជាសត្វយ៉ាងសំខាន់មួយដែលជួយអោយដីមានជីជាតិល្អ ។ ការប្រើថ្នាំពុលអាចប៉ះពាល់ដល់ សកម្មភាពរបស់សត្វរស់នៅក្នុងដី ដែលនាំអោយជីជាតិដីថយចុះ ការលូតលាស់ដំណាំមិនសូវបានល្អងាយស្រួលបំផ្លាញពីកត្តាចង្រៃផ្សេងៗ ។ អ្វីដែលយើងគួរព្រួយបារម្ភ

ខ្លាំងដែរនោះគឺ ឥទ្ធិពលនៃការប្រើប្រាស់ថ្នាំពុលលើត្រី ។ ត្រី មិនត្រឹមតែជាមិត្តរបស់កសិករមួយដ៏សំខាន់ទេតែវាជាអាហារចាំបាច់សំរាប់ប្រជាជនខ្មែរយើង ។ ថ្នាំពុលជាច្រើនប្រភេទ ងាយពុលដល់ត្រីហើយជួនកាលភាពពុលរបស់វាមានកំរិតលើសពីការ ស្មានរបស់យើងផង (សូមអាន រឿងក្នុង ប្រអប់ទី ៦)

ដូចនេះ ដើម្បីកុំអោយធម្មជាតិបាត់បង់នូវសត្វមានប្រយោជន៍ផ្សេងៗ និង ចៀសវាងកុំអោយមានការផ្ទុះឡើងនូវកត្តាចង្រៃ សូមលោក-អ្នកពិចារណាអោយបានច្បាស់លាស់ពេលប្រើថ្នាំពុល ។ ដើម្បីជាជំនួយក្នុងការសំរេចចិត្តរបស់លោកអ្នក យើងបានរៀបជាបញ្ជីឈ្មោះថ្នាំ ដែលបង្ហាញអំពីថ្នាំណាខ្លះដែលពុលខ្លាំងដល់ត្រី ឃ្មុំ ។ បញ្ជីនេះមាននៅទំព័រចាប់ពីទី ៦០ ដល់ ៦៣ នៃផ្នែកខាងក្រោយនៃសៀវភៅនេះ ។

**ប្រអប់ទី ៦: ថ្នាំពុល និងត្រី**

កសិករ **ឡេង ជា** រស់នៅភូមិបញ្ញាជី ឃុំត្បូងក្រពើ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ បានបាញ់ថ្នាំរូបកូរស្រូវ (Thiodan) ដើម្បីការពារការបំផ្លាញដោយដង្កូវលើស្រូវវស្សារបស់គាត់កាលពីរដូវវស្សាឆ្នាំ ១៩៩៩ ។ គាត់បានបាញ់ថ្នាំដោយប្រើទឹកថ្នាំចំនួន ៤ ធុង លើផ្ទៃដីប្រហែល ១០ អា ដោយក្នុងមួយធុងគាត់លាយថ្នាំ ១គំរបកំប៉ុង ។ ស្អែកព្រលឹមឡើង គាត់បានទៅមើលស្រែរបស់គាត់ស្រាប់តែឃើញមានត្រី និងអន្ទង់ ងាប់ពេញស្រែ ។ គាត់មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ហើយតាំងពីពេលនោះមកគាត់ឈប់ប្រើថ្នាំលើស្រូវវស្សាហើយ ។

## គ. ភាពស៊ាំរបស់កត្តាចង្រៃ

នៅពេលយើងបាញ់ថ្នាំច្រើនទៅ ពេលនោះពពួកដែលបំផ្លាញដំណាំមួយចំនួនធំលែងសូវចាញ់ជាតិថ្នាំ មានន័យថា *វាចាប់ផ្តើមស៊ាំនឹងជាតិថ្នាំហើយ* ។ ឧទាហរណ៍ តាមលទ្ធផលនៃការស្រាវជ្រាវនៅចន្លោះឆ្នាំ ១៩៣៨ ដល់ ១៩៨៤ គេសង្កេតឃើញថា ចំនួនសត្វល្អិតដែលស៊ាំទៅនឹងថ្នាំពុលបានកើនឡើងពី ៧ ដល់ ៤៤៧ ប្រភេទ ។ តាមការអនុវត្តន៍ជាក់ស្តែង ដើម្បីឱ្យយើងអាចយកឈ្នះលើពពួកសត្វដែលស៊ាំនេះ គឺវាទាមទារឱ្យយើងបាញ់ថ្នាំ ក្នុងកំរិតកាន់តែខ្លាំង និងបាញ់កាន់តែញឹក (រហូតដល់ជួនកាលរាល់ថ្ងៃ ឬ មួយថ្ងៃ ២ ដង) ។ ទន្ទឹមនឹងនេះ វាក៏ទាមទារឱ្យយើងលាយប្រភេទថ្នាំច្រើនមុខចូលគ្នា និងដូរកប្រភេទថ្នាំដែលខ្លាំងជាងមុន ។

អ្នកប្រើថ្នាំ ដែលឈានចូលដល់ដំណាក់កាលរបៀបនេះ គេហៅថាចូលមកដល់ "*ភាពញៀននៃថ្នាំពុល*" ហើយ ។ ដំណាក់កាលនេះ ជាដំណាក់កាលមួយគ្រោះថ្នាក់ណាស់ ពីព្រោះយើងត្រូវទទួលរងភាពពុលកាន់តែខ្លាំងជាងមុន ចំណាយកាន់តែច្រើន ហើយជួនកាលអត់បានផលសំរាប់លក់ និងហូបផង ។

ការបាត់បង់សត្រូវធម្មជាតិ ឬសត្វមានប្រយោជន៍ និងការចូលដល់ដំណាក់កាលដែលសត្វបំផ្លាញស៊ាំនឹងថ្នាំពុល ហើយពពួកស៊ាំនេះរីកដុះដាលខ្លាំង ឬផ្ទុះចេញមកខ្លាំង គឺជាសញ្ញាមួយប្រាប់ថា "*ធម្មជាតិវាយតបមកវិញហើយ*" ។ ឈានចូលមកដល់ដំណាក់កាលនេះ មានកសិករមួយចំនួនបានចុះចាញ់ធម្មជាតិយ៉ាងសមរម្យ តែក៏មានកសិករខ្លះចង់យកឈ្នះដែរ ។ តែទីបំផុតគេបានត្រឹមតែបាត់បង់ថវិកាយ៉ាងច្រើន ហើយជួបនូវភាពទ្រុឌទ្រោម នៃសុខភាពរបស់ខ្លួនតែប៉ុណ្ណោះ ។

**ប្រអប់ទី ៧: បញ្ហាទាក់ទងចង់យកឈ្នះលើសត្វល្អិត**

អ្នកមីង **ខន** នៅភូមិព្រៃកក្តី ឃុំព្រែកតាទែន ស្រុកពញាឮ ខេត្តកណ្តាល បានពុលថ្នាំដោយសារការចង់យកឈ្នះលើសត្វល្អិត ។ គាត់បានប្រើថ្នាំ ៣-៤ មុខលាយបញ្ចូលគ្នា ដើម្បីបាញ់ទៅលើសណ្តែក ។ ក្នុងករណីមានការបំផ្លាញពីសត្វល្អិតខ្លាំង គាត់បានបង្កើនរយៈពេលបាញ់ថ្នាំរហូតដល់ ១ ថ្ងៃបាញ់ម្តង តែការបំផ្លាញរបស់វានៅតែមានទៀត គាត់ក៏បានបង្ខំចិត្តចាប់ដង្កូវដាក់ចូលក្នុងស្បោង ដែលមានថ្នាំពុលជាប្រភេទម្សៅម្យ៉ាង ។ ដោយការបើកបិតមាត់ស្បោងចុះឡើងៗ បានធ្វើអោយជាតិថ្នាំពុលចូលទៅក្នុងខ្លួនគាត់តាមរយៈការដកដង្ហើម ហើយបណ្តាលអោយគាត់ពុលទន់ខ្លួនតែម្តង ។

## ឃ. ការបន្សល់ទុកនូវជាតិថ្នាំក្នុងបរិស្ថាន

មានថ្នាំពុលខ្លះមិនអាចរលាយសាបអស់ងាយស្រួលទេ បន្ទាប់ពីប្រើហើយ វាអាចនៅសល់ក្នុងដី ទឹក និងរាងកាយរបស់សត្វ និងមនុស្ស រហូតដល់រាប់ឆ្នាំ (ឧទាហរណ៍ ម្សៅដេ ដេ តេ) ។ ភាពមិនងាយរលាយ ឬសាប ដោយសារថ្នាំទាំងនោះវាមិនរលាយក្នុងទឹក តែរលាយនៅពេលប៉ះជាតិខ្លាញ់ ។ ដូចនេះ ពេលវាធ្លាក់ចូលដល់ក្នុងទឹក បរិមាណថ្នាំខ្លះត្រូវទើរនៅក្នុងរុក្ខជាតិ និងសត្វល្អិតនៅក្នុងទឹក (ភាសាបច្ចេកទេស គេហៅថា *ប្លង់តុង*) ។

ជាតិពុលនេះ ត្រូវបានឆ្លងបន្តពីសត្វមួយទៅសត្វមួយ ហើយជូនកាលរហូតដល់មនុស្ស តាមរយៈការស៊ីគ្នា ១ គ្នា *(ច្រវាក់ចំណីអាហារ)* ហើយកំហាប់ថ្នាំពុលចេះតែកើនឡើង១ ។ ការកើនឡើងនៃកំហាប់ថ្នាំពុលនោះ ដោយសារសត្វធំមួយត្រូវស៊ីសត្វតូចច្រើន ។ ដូចនេះ បរិមាណថ្នាំពុលដែលមាននៅសត្វតូច១ ត្រូវប្រមូលផ្តុំនៅក្នុងសត្វធំ ។ ឧទាហរណ៍ កសិករម្នាក់បាញ់ថ្នាំ ហើយថ្នាំនោះហូរចូលមកក្នុងទឹក ហើយបន្សល់ទុកនូវកូនដង្កូវតូច១ (ប្លង់តុង) ។ កូនត្រីក៏ស៊ីកូនដង្កូវនេះ ហើយកូនត្រីត្រូវស៊ីដោយត្រីធំផ្សេង១ទៀត ហើយត្រីនេះអាចត្រូវសត្វ កុកចាប់ស៊ី ឬត្រូវមនុស្សចាប់បរិភោគ ។ ឆ្លងតាមរយៈការស៊ីគ្នានេះ នាំឱ្យជាតិថ្នាំអាចចូលមកដល់ខ្លួនមនុស្សយើង ឬសត្វផ្សេង១ ទៀត ដោយកំហាប់របស់ថ្នាំអាចកើនរហូតទៅដល់រាប់លានដង ។

**ប្រអប់ទី ៨ : ផលវិបាកនៃការប្រើថ្នាំដែលមិនងាយរលាយ**

◆ នៅសហរដ្ឋអាមេរិក កាលពីប្រហែល ៣០ ឆ្នាំ មុនគេសង្កេតឃើញសត្វស្លាប ម្យ៉ាងដែលពីមុនធ្លាប់សំបូរ តែក្រោយមកចេះតែថយចុះទៅ១ រហូតសឹងតែបាត់បង់ពូជ ។ បន្ទាប់ពីធ្វើការស្រាវជ្រាវមកគេរកឃើញថា សត្វស្លាបនេះបានស៊ីសត្វល្អិតផ្សេង១ និងកូនត្រីដែលរស់នៅក្នុងបឹង ដែលមានជាតិថ្នាំ ដេដេតេហូរចូល ។ តាមពិតជាតិ ដេ ដេ តេ ដែលមានក្នុងបឹង មានកំរិតទាបណាស់ តែដោយសារតាមរយៈស៊ីគ្នា១គ្នារាប់ឆ្នាំមក ធ្វើអោយបរិមាណ ដេ ដេ តេ ចេះតែកើនឡើងក្នុងខ្លួនសត្វស្លាបនោះ ។ ដោយសារមានជាតិថ្នាំពុលនៅក្នុងខ្លួនធ្វើអោយសត្វនេះពងចេញមកចេះតែបែក មិនអាចបន្តញាស់កូនចៅបាន (សូមមើលរូបភាពទី ១៥ )

◆ នៅប្រទេសនីការ៉ាហ្គ័រ ( ប្រទេសមួយនៅទ្វីបអាមេរិកកណ្តាល) ក្នុងឆ្នាំ ១៩៧៧ គេបានរកឃើញថាប្រជាជននៅទីនោះមានបន្ទុកជាតិ ដេដេតេ ក្នុងខ្លួនចំនួន ៣១ ដង ច្រើនជាងជនជាតិអាមេរិក ។ នេះដោយសារនៅប្រទេសនីហ្គារ៉ាហ្គ័រ មានការប្រើថ្នាំ ដេដេតេ ខ្លាំង ចំណែកនៅសហរដ្ឋអាមេរិក ដេដេតេត្រូវបានហាមមិនឱ្យប្រើតាំងពីឆ្នាំ ១៩៧២ មក ម្ល៉េះ ។

**រូបភាពទី១៥ : ភាពកើនឡើងនៃបរិមាណថ្នាំពុលក្នុងខ្លួនសត្វតាមរយៈការស៊ីគ្នា ក្នុងរយៈពេលយូរ**




ដោយសារពពួកថ្នាំដែលមិនងាយរលាយ ហើយចេះតែស្ថិតនៅយូរអង្វែង នាំមកនូវគ្រោះថ្នាក់ដល់បរិស្ថាន ក៏ដូចជាសុខភាពរបស់យើង ដូចនេះសូមបងប្អូនកសិករជៀសវាងកុំប្រើថ្នាំទាំងនេះ ជាពិសេសថ្នាំ ដេ ដេ តេ ។ ដើម្បីអោយលោកអ្នកដឹងថា ថ្នាំណាខ្លះដែលមាននៅលើទីផ្សារស្រុកខ្មែរ ជាពពួកថ្នាំដែលមិនងាយរលាយ សូមអានបញ្ជីរាយថ្នាំនៅទំព័រ ៦៤ តារាងទី ៤។

## ២.៣. ថ្នាំពុល និងបញ្ហាដែលកើតមានឡើងក្នុងសហគមន៍

នៅពេលដែលកសិករបាញ់ថ្នាំសំលាប់សត្វល្អិត វាអាចធ្វើអោយក្លិនថ្នាំពុលសាយភាយពាសពេញភូមិដែលពួកគាត់រស់នៅ ហើយធ្វើអោយមានការប៉ះពាល់ដល់អ្នកជិតខាងរបស់គាត់ ។ មានករណីខ្លះកើតមានជម្លោះប្តឹងផ្តល់គ្នាទៀតផង ។ ចំពោះការដាក់ថ្នាំសំលាប់កណ្តុរ ឬការប្រើថ្នាំលើស្រែដែល មិនបានដាក់បំរាមហាមអោយគេដឹង ក៏ជាកត្តាមួយដែលធ្វើអោយមានគ្រោះថ្នាក់ដល់អ្នកផ្សេងទៀត ។

**ប្រអប់ទី ៩: រឿងពិតនៅក្នុងប្រទេសកម្ពុជា**

- ក្រុមគ្រួសារមីង **ពក** រស់នៅក្នុងភូមិទួលក្រាំង ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្តាលបានអះអាងថា សមាជិកគ្រួសារគាត់ចំនួន ៩ នាក់ ក្នុងចំណោម ២១ នាក់ បានទទួលនូវជំងឺដោយសារអ្នកជិតខាងរបស់គាត់ប្រើថ្នាំពុលលើដំណាំបន្លែអស់រយៈពេល ៨ឆ្នាំ ។ អ្នកទាំងនោះមានជំងឺលើសឈាម ការខ្សោយចុះកំលាំង ឈឺក្រពះ និងរោគសួត ។ ករណីនេះកើតមានឡើងនៅខែសីហា ឆ្នាំ ១៩៩៩ ។
- គ្រួសារម្នាក់នៅក្នុងភូមិលេខ ២ ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល បានប្តឹងអ្នកជិតខាង របស់គាត់ពីការប្រើប្រាស់ថ្នាំពុលលើជង្រុកស្តុកពោត ដែលបានធ្វើអោយសមាជិកក្នុងគ្រួសាររបស់គាត់៦ នាក់ពុល (៤ នាក់ស្រាល និង ២ នាក់ទៀតធ្ងន់) ។ ការប្តឹងនេះបានបន្តរហូតដល់ ចៅហ្វាយស្រុក ។ ករណីនេះកើតមានឡើង នៅខែ ធ្នូ ឆ្នាំ ១៩៩៩ ។
- បងស្រីម្នាក់រស់នៅក្នុងស្រុក មេសាង ខេត្តព្រៃវែង បានពុលថ្នាំ ដោយគាត់បានហូបទឹកពីក្នុងស្រែដែលគេទើបតែបាញ់ថ្នាំហើយ ។ គាត់ត្រូវបានគេបញ្ជូនទៅមន្ទីរពេទ្យ ដើម្បីធ្វើការព្យាបាល (១៩៩៥) ។

ការប្រើថ្នាំសំលាប់កណ្តុរ ធ្វើអោយមានការប៉ះពាល់ដល់សត្វចិញ្ចឹមក្នុងស្រុក មានដូចជា មាន់ ទា ជ្រូក ជាដើម ដែលស៊ីនុយ ។ តែចំពោះការពុលដល់សត្វគោអ្នកជិតខាង ច្រើនតែកើតឡើងក្នុងករណីដែលម្ចាស់ច្រូតស្មៅក្នុងចំការដំណាំ ដែលទើបបាញ់ថ្នាំហើយ ឬគោទៅស៊ីកន្លែងដែលគេទើបបាញ់ថ្នាំហើយ ។

**រូបទី ១៦: អ្នកជិតខាងឈ្លោះទាស់ទែងគ្នាដោយសារការប្រើថ្នាំពុល**



**ប្រអប់ទី ១០ : រឿងពិតកើតមាននៅក្នុងប្រទេសកម្ពុជា**

- នៅក្នុងភូមិទ្រា ឃុំឈើកាច់ ស្រុកបាភ្នំ ខេត្តព្រៃវែង មានជម្លោះយ៉ាងខ្លាំង រវាងអ្នកដាក់ថ្នាំកណ្ដុរ និងម្ចាស់មាន់ ។ ដោយអ្នកដាក់ថ្នាំកណ្ដុរមិនបានយកចេញ ហើយធ្វើអោយមាន់អ្នកភូមិងាប់១០ ក្បាល ករណីនេះកើតមានឡើងនៅខែ កក្កដា ១៩៩៩ ។
- កសិករម្នាក់នៅក្នុងភូមិកោះខែល ឃុំកោះខែល ស្រុកស្អាងបានទៅច្រូតស្មៅអោយគោស៊ី ។ ស្មៅដែលគាត់ច្រូតគឺជាកន្លែងដែលគេទើបតែបាញ់ថ្នាំពុលហើយ ២ថ្ងៃ ។ នៅពេលដែលគោគាត់ស៊ី វាហើមពោះ រយៈពេលក្រោយមកគោគាត់ងាប់ ។

បញ្ហាផ្សេងៗ ទៀត ដែលអាចបង្កអោយមានទំនាស់ក្នុងសហគមន៍ គឺការបោះសំបកដបថ្នាំចោលពាសវាលពាសកាល ។ ជួនកាលមានអ្នកខ្លះ ឬក្មេងអាចរើសសំបកដបទៅលេង ឬយកទៅប្រើក៏បណ្ដាលអោយពុលដែរ

ដូចនេះក្នុងករណីដែលយើងត្រូវតែប្រើថ្នាំពុល សូមយើងគិតគូរដល់អ្នកជិតខាងក៏ដូចជាអ្នក ដែលរស់នៅក្នុងភូមិជាមួយយើងផង ។ ភាពពុលរបស់ថ្នាំពុល វាគ្មានព្រំដែនច្បាស់លាស់ទេ ។ ដើម្បីជៀសវាងនូវទំនាស់ យើងគួរតែមានការជូនដំណឹងដល់អ្នកដទៃទុកជាមុន ឬមានការដាក់សញ្ញាសំរាប់សំគាល់ អោយដឹងថា ស្រែ ឬចំការរបស់យើងមានបាញ់ថ្នាំពុល ។

## ២.៤. ថ្នាំពុល និងស្ថេរភាពនៃមុខរបរចិញ្ចឹមជីវិត

ការប្រើថ្នាំពុលអាចធ្វើអោយកសិករបាត់បង់នូវមុខរបររបស់ខ្លួន ឬដូរមុខរបរដោយសារការកើននៃការចំណាយ ការចុះទ្រុឌទ្រោមនៃកម្លាំង និងការប៉ះពាល់ដល់សុខភាពអ្នកបរិភោគ ។

### ក. ការកើនឡើងនៃការចំណាយ

កសិករភាគច្រើនចូលចិត្តប្រើប្រាស់ថ្នាំពុលគីមី ដើម្បីការពារដំណាំរបស់គាត់ ព្រោះគាត់យល់ថាវាមានប្រសិទ្ធិភាពរហ័សទាន់ចិត្ត និងងាយស្រួលប្រើ។ ក៏ប៉ុន្តែ បន្ទាប់ពីប្រើយូរទៅៗ គាត់យល់ថាការចំណាយលើការប្រើថ្នាំនេះចេះតែកើនឡើងៗ ។

នេះដោយសារគាត់ប្រើថ្នាំពុលយូរទៅៗ ធ្វើអោយសត្វល្អិតចង្រៃ មានលក្ខណៈធន់ទៅនឹងថ្នាំពុល (វាស្គាល់ថ្នាំ) ដែលធ្វើអោយប្រសិទ្ធិភាពរបស់ថ្នាំពុលមានការថយចុះ ។ ដើម្បីចង់អោយសត្វល្អិតបំផ្លាញដំណាំងាប់ គាត់ត្រូវបង្កើនបរិមាណថ្នាំកាន់តែច្រើន បាញ់ថ្នាំកាន់តែញឹក លាយថ្នាំចូលគ្នាកាន់តែច្រើនមុខ ។

ក្នុងដំណាក់កាលនេះ ធ្វើអោយគាត់មានការចំណាយកាន់តែច្រើន ហើយការចំណេញក៏កាន់តែតិច ។ ហើយបើនៅពេលប្រមូលផល បន្លែចុះថោកទៀតនោះ វាអាចនាំអោយការដាំដុះរបស់គាត់ខាតបង់ប្រាក់ទៀតផង ។

**ប្រអប់ទី១១ ៖ រឿងពិតទាក់ទងការចំណាយលើការដាំដុះកើនឡើង**

កសិករដាំបន្លែម្នាក់នៅភូមិអូររំចេក ឃុំស្វាយប្រទាល ស្រុកស្អាងខេត្តកណ្ដាល ដាំខាត់ណាឈើ លើផ្ទៃដី ៥៧៦ ម៉ែត្រការ៉េ ។ គាត់ប្រើថ្នាំពុល ៨ មុខចំរុះចូលគ្នា ហើយធ្វើការបាញ់ប្រមាណជា ៣០ ដងលើដំណាំខាត់ណា ។ គាត់ចំណាយលើថ្នាំពុលប្រមាណ ១២០០០០០ រៀល(ប្រមាណ ជា ៨៥ ភាគរយនៃការចំណាយទាំងអស់) ។ ផលដែលគាត់ទទួលបាន ១០០០ គ.ក្រ ហើយលក់បានក្នុងមួយគីឡូក្រាម ១៤០០រៀល ។ ដូចនេះ គាត់អាចទទួលបានប្រាក់ចំណេញ ប្រមាណតែ បួនម៉ឺនរៀលទេ (៤០០០០រៀល) ។ តែបើសិនជាផលគាត់ទទួលបានតិចជាងនេះ (១០០០គក្រ) ឬតំលៃតិចជាង ១៣០០រៀលក្នុងមួយ គីឡូក្រាម នោះការដាំដុះរបស់គាត់ពិតជាខាត ។

## ខ. ការប៉ះពាល់ដល់សុខភាពអ្នកបរិភោគបន្លែ

កសិករភាគច្រើនគាត់បាញ់ថ្នាំចុងក្រោយលើដំណាំបន្លែតែ ២ ឬ ៣ ថ្ងៃទេមុនពេលប្រមូលផលយកទៅលក់ ។ ក្នុងករណីដែលមានសត្វបំផ្លាញច្រើន គាត់បាញ់ភ្លាមប្រមូលផលភ្លាម ព្រោះគាត់ការពារដំណាំរបស់គាត់កុំអោយមានស្នាមសត្វស៊ីខ្លាំងពេក នៅពេលយកទៅលក់វាមិនបានថ្លៃ ។ ក្នុងរយះពេលនេះ សារធាតុថ្នាំពុលវាស្ថិតនៅក្នុងបន្លែ ឬដំណាំផ្សេងៗទៀតនៅឡើយ (សូមអានប្រអប់ទី ១២) ។

**ប្រអប់ទី១២ ៖ រយះពេលដែលអាចប្រមូលផលបានបន្ទាប់ពីបាញ់ថ្នាំ**

- ថ្នាំម៉ូនីទ័រ (Monitor) ដែលកសិករយើងហៅថាទឹកស្អុយវាត្រូវការរយះពេល ២១ថ្ងៃ ទើបអាចប្រមូលផលបាន បន្ទាប់ពីបាញ់ចុងក្រោយ ។
- ថ្នាំមេវីនហ្វូស (Mevinphos) កសិករហៅថារូបផ្ទិត វាត្រូវការ ១៥ថ្ងៃ ទើបអាចប្រមូលផលបាន បន្ទាប់បាញ់ចុងក្រោយ ។
- ថ្នាំហ្វូលីដុល (Folidol) កសិករហៅដេវ៉ា រយះពេល ១៤ ថ្ងៃទើប អាចប្រមូលផលបាន បន្ទាប់ពីបាញ់ចុងក្រោយ ។

នៅពេលដែលអ្នកបរិភោគទិញបន្លែយកទៅហូបមានបញ្ហា នោះវាអាចធ្វើអោយផលិតផលរបស់កសិករលក់មិនសូវដាច់ទេ ។

**ប្រអប់ទី១៣ : រឿងពិតទាក់ទងអ្នកហូបបន្លែពុលថ្នាំ**

ក្រុមគ្រួសាររបស់កញ្ញា **សុយ រស្មី** រស់នៅក្នុងទីក្រុងភ្នំពេញ ធ្លាប់ពុលបន្លែខាត់ណាឈីកាលពី ៣ ឆ្នាំមុន ។ គ្រួសារនេះបានទិញខាត់ណាឈើយកមកឆាជាមួយសាច់គោ ហើយពេលហូបទៅ សមាជិក ៩ នាក់ពុលទាំងអស់ ដោយមានរាគផងនិងក្អួតផង ក្នុងនោះមានម្នាក់សន្លប់ រហូតដល់ដឹកទៅមន្ទីរពេទ្យ។ បច្ចុប្បន្នគ្រួសារនេះបានកាត់បន្ថយការហូបបន្លែស្លឹកដែលទិញពីទីផ្សារហើយ ។

## គ. ការបាត់បង់កំលាំងពលកម្ម និងការចំណាយលើការថែរក្សាសុខភាព

ពេលកសិករប្រើថ្នាំពុលយូរទៅៗ ថែមទាំងមិនសូវមានការប្រុងប្រយ័ត្នក្នុងពេលបាញ់ ធ្វើអោយមានការប៉ះពាល់ដល់សុខភាព ។ សុខភាពរបស់គាត់មានបញ្ហានោះ ធ្វើអោយកំលាំងពលកម្មក្នុងគ្រួសារមានការបាត់បង់ ហើយឈានទៅដល់ការបោះបង់ចោលនូវអាជីវកម្មរបស់គាត់ផង ។

**ប្រអប់ទី ១៤: រឿងពិតទាក់ទងអ្នកពុលថ្នាំ**

- លោកពូ **នុល** ជាអ្នកពូកែដាំបន្លែនៅឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល ដោយសារមានជំងឺរ៉ាំរ៉ៃជាប់ជាប្រចាំ ធ្វើអោយគាត់បោះបង់ចោលការដាំដុះ ហើយការងារសំខាន់របស់គាត់ក្នុងពេលនេះគឺជួយការងារប្រពន្ធ និងមើលកូននៅផ្ទះ។
- ពូ រស់ ឈុន ជាអ្នកធ្វើស្រែចំការនៅក្នុងភូមិ ត្នោតទ្រេត ឃុំតាកោ ស្រុកកំពង់លាវ ខេត្តព្រៃវែង ដោយការប្រើថ្នាំពុលយូរទៅ ធ្វើអោយកំលាំងរបស់គាត់ចុះខ្សោយយ៉ាងខ្លាំង ។ នៅពេលត្រូវការបាញ់ថ្នាំ ឬ ធ្វើ ការងារផ្សេងៗ ទៀត ក្នុងដំណើរការដាំដុះ គាត់ត្រូវការជួលគេវិញ ។

សរុបមក នៅពេលដែលយើងប្រើប្រាស់ថ្នាំពុលកាន់តែច្រើន ធ្វើឱ្យយើងចំណាយកាន់ក៏តែច្រើន ប្រាក់ ចំណេញដែលទទួលបានកាន់តែតិចទៅៗ ផលិតផលរបស់យើងគេមិនសូវទិញ ហើយសុខភាពរបស់យើង កាន់តែទ្រុឌទ្រោមទៅៗ ។ ហេតុផលទាំងនេះ បានធ្វើអោយប៉ះពាល់ដល់និរន្តរភាពរបស់អាជីវកម្មយើង ។

**រូបភាពទី១៧ : ការលំបាករបស់កសិករដោយសារប្រើថ្នាំពុលខុសរបៀប(ចំណាយលើការទិញថ្នាំកាន់តែច្រើន ខ្លួនកាន់តែទ្រោម ចំណាយលើការព្យាបាលកាន់តែខ្លាំង)**



# ជំពូកទី ៣ ៖ ការកាត់បន្ថយភាពគ្រោះថ្នាក់របស់ថ្នាំពុលដល់សុខភាព និងបរិស្ថាន

**គោលបំណង៖**

- បន្ទាប់ពីសិក្សាជំពូកនេះចប់ អ្នកនឹងអាចបានយល់បន្ថែមនូវអ្វី ដែលអ្នកត្រូវប្រុងប្រយត្ន័ នៅពេលបាញ់ និងអ្វីដែលអ្នកត្រូវជៀសវាងឬអនុវត្តនៅពេលធ្វើការជាមួយថ្នាំពុល

- ការអនុវត្តតាមគំនិត និងចំណុចណែនាំ ក្នុងជំពូកទី ៣ នេះអាចជួយអោយអ្នកកាត់បន្ថយ នូវឥទ្ធិពលមិនល្អរបស់ថ្នាំពុលទៅលើសុខភាពរបស់អ្នក គ្រួសារអ្នក និងបរិស្ថានរបស់ យើង

# ជំពូកទី ៣ : ការកាត់បន្ថយភាពគ្រោះថ្នាក់របស់ថ្នាំពុលដល់សុខភាព និងបរិស្ថាន

ដើម្បីជៀសវាងនូវបញ្ហាដែលកើតមានឡើងដោយសារថ្នាំពុល មានតែផ្លូវម្យ៉ាងទេគឺ *កុំប្រើវាតែម្តង* ។ មានមធ្យោបាយជាច្រើនដែលអាចអោយយើងជៀសពីការប្រើថ្នាំពុល ឬ ប្រើវាក្នុងកំរិតតិចបំផុត (សូមអានសៀវភៅស្តីពីវិធានការផ្សេងៗ ក្នុងកិច្ចការពារដំណាំ) ។ ប៉ុន្តែ នេះជាការលំបាកក្នុងការកែទំលាប់របស់បងប្អូនកសិករយើង ដោយសារយើងនៅតែយល់ថា ថ្នាំពុលជាមធ្យោបាយដែលមានប្រសិទ្ធិភាព ហើយជាបច្ចេកទេសទំនើប ។ ដូចនេះ ក្នុងករណីលោកអ្នកនៅតែចង់ ឬ ត្រូវតែប្រើថ្នាំពុល យើងខ្ញុំសូមជូនយោបល់ ខ្លះៗ ដើម្បីជួយធានានូវសុវត្ថិភាពក្នុងការប្រើថ្នាំ ។

យោបល់ណែនាំផ្តោតទៅលើសកម្មភាពមុនពេលបាញ់ ពេលបាញ់ ក្រោយពេលបាញ់ ក៏ដូចជាការទុកដាក់ថ្នាំ និងសំបកថ្នាំ ។ ចំណុចណែនាំភាគច្រើន យើងធ្វើពិណ៌នាតាមរូបភាព ដែលមាននៅតាមទំព័របន្ទាប់ពីនេះ ។ ចំណុចសំខាន់មួយទៀត ដែលយើងខ្ញុំចង់រំឭកដល់ លោក-អ្នកដែរ គឺគ្មានថ្នាំការពារដំណាំណាដែលមិនពុលទេ គ្រាន់តែកំរិតពុលរបស់វាខុសគ្នា ហើយជូនកាលវាពុលភ្លាម តែជួនកាលវាចាប់ផ្តើមចេញរោគសញ្ញាបន្ទាប់ ពីប្រើច្រើនឆ្នាំមក ។ ទន្ទឹមនឹងនេះ យើងខ្ញុំសូមរំឭកផងដែរថា ប្រសិនបើលោកអ្នកត្រូវតែប្រើថ្នាំការពារដំណាំដោយជៀសវាងមិនបាន យើងមានសំណូមពរដូចខាងក្រោមនេះ :

- សូមជៀសវាងប្រើថ្នាំដែលមានកំរិតពុលខ្លាំងដល់មនុស្ស (សូមអានតារាងទី ១)
- ជៀសវាងប្រើថ្នាំដែលមានបន្សល់ជាតិពុលយូរក្នុងបរិស្ថាន(សូមអានតារាងទី ៤)
- សូមជៀសវាងប្រើថ្នាំដែលពុលខ្លាំងដល់ត្រី និងឃ្មុំ (សូមអានតារាងទី២និងទី៣)
- ជៀសវាងលាយថ្នាំច្រើនមុខចូលគ្នា
- ជៀសវាងលាយថ្នាំទៅតាមការនឹកឃើញ
- ជៀសវាងបាញ់ថ្នាំរហូតដល់ថ្ងៃប្រមូលផល
- ជៀសវាងបណ្តោយអោយមនុស្សចូលចំការដែលទើបនឹងបាញ់ថ្នាំហើយ ( ចំពោះថ្នាំដែលពុលខ្លាំងគឺពួកក្រុម ១ ហាមចូលក្នុងរយៈពេល ៤៨ ម៉ោង ដល់ ៧២ ម៉ោង ក្រោយពេលបាញ់ហើយ )

យោបល់ និងសំណូមពរផ្សេងៗទៀតដើម្បីធានានូវសុវត្ថិភាពខ្លះៗ ក្នុងការប្រើថ្នាំពុល យើងខ្ញុំមានបង្ហាញដូចរូបភាពបន្តបន្ទាប់នៅទំព័រខាងមុខនេះ ។



☞ នៅពេលទៅ
ទិញថ្នាំសូមកុំដាក់
ថ្នាំពុលឡូកឡំចំណី
អាហារ ទោះបីជាដប
ថ្នាំបិទជិតក៏ដោយ



☛ ត្រូវមានសំលៀកបំពាក់ និងឧបករណ៍ការពារសំរាប់ប្រើក្នុងពេលបាញ់ថ្នាំ





☛ ចៀសវាងនូវការដាក់ជើងខោក្នុងស្បែកជើង អាចនាំអោយទឹកថ្នាំចូលបាន



☛ យ៉ាងហោចណាស់ពេល
បាញ់និងលាយថ្នាំត្រូវយក
ក្រណាត់រុំមុខ



☛ គួរស្លៀកពាក់ដូចនេះ



☛ សូមធ្វើការប្រុងប្រយ័ត្នក្នុងការលាយថ្នាំដើម្បីកុំអោយប៉ះពាល់លើខ្លួនប្រាណ





☛ ជៀសវាងកុំអោយមនុស្ស និងសត្វមកជិតចំការបាញ់ថ្នាំ និងកន្លែងលាយថ្នាំ



☛ កុំពាក់អាវរហែកបាញ់ថ្នាំ



☛ ពេលសំលៀកបំពាក់រហែក សូមដេរអោយជិតមុនយកមក
ពាក់ការពារខ្លួនពេលបាញ់ថ្នាំ



☛ ហាមបាញ់ថ្នាំក្នុងពេលមានភ្លៀង ព្រោះវាអាចបន្សាបថ្នាំ និងធ្វើអោយមានភាពកខ្វក់ដល់បរិស្ថាន



☛ ហាមបាញ់ក្នុងពេលថ្ងៃត្រង់ ព្រោះវាអាចប៉ះពាល់ដល់សុខភាព (ថ្នាំអាចជ្រាបចូលតាមរន្ធញើស) និងអាចប៉ះពាល់ដល់ការលូតលាស់ដំណាំ ។ សូមបាញ់ពេលរសៀល ឬព្រឹកជាការប្រសើរបំផុត ។ ណាមួយបាញ់ពេលថ្ងៃក្តៅខ្លាំងធ្វើអោយពិបាកស្មៀកពាក់ដោយវាក្តៅស្អុះខ្លាំង ។



☛ សូមហាមក្មេងបាញ់ថ្នាំព្រោះក្មេងឆាប់ពុលជាងមនុស្សពេញវ័យណាស់



☛ ពេលបាញ់សូមពិនិត្យមើលទិសខ្យល់ បើបាញ់បញ្ច្រាស់ខ្យល់វាអាចជះទឹកថ្នាំមកលើខ្លួនយើង

## របៀបបាញ់ថ្នាំដោយសុវត្ថិភាពតាមរយៈការដូរដៃ

ដំបូងបំផុតមុននឹងបាញ់ យើងត្រូវពិនិត្យមើលទិសខ្យល់ដោយធ្វើយ៉ាងណាយើងត្រូវស្ថិតនៅពីលើខ្យល់ជានិច្ច ។ តាមរូបខាងក្រោម តំបូងយើងស្ថិតនៅត្រង់ចំណុចទី ១ ដោយបាញ់ប្រើដៃស្តាំ ហើយយើងធ្វើការវៀសបាញ់ចាប់ពីខ្នងរហូតដល់ចំហៀងខ្លួន (អោយបានកែង ៩0 ដឺក្រេ) ។ យើងបាញ់របៀបនេះ ពីចុងភ្លឺម្ខាងដល់ចុងម្ខាងទៀតបន្ទាប់មកយើងរំកិលឡើងលើដល់ចំណុចទី ២ ហើយធ្វើការដូរបាញ់ដៃឆ្វេងម្តងវិញ ។ យើងធ្វើការដូរដៃរបៀបនេះបន្តពីចំណុចទី៣, ៤ ទី ៥ រហូត ដល់ចុងបញ្ចប់ស្រែរបស់យើង ។





ចៀសវាងពិសារបារី ឬ ម្ហូបអាហារនៅពេលមិនទាន់លាងសំអាតខ្លួន
ប្រាណបន្ទាប់ ពីបាញ់ថ្នាំហើយ



សូមសំអាតខ្លួនប្រាណ
និង សំលៀកបំពាក់ក្រោយ
ពេលបាញ់ ជាមួយសាប៊ូ



☛ សូមចៀសវាងការបាញ់ទៅលើដំណាំដែលស្ថិតនៅខ្ពស់ពីខ្លួនយើងវាគ្រោះថ្នាក់ខ្លាំង





☛ ការដាក់ផ្លាកសញ្ញាលើស្រែទើបបាញ់ថ្នាំហើយ អាចជួយការពារការគ្រោះថ្នាក់ដល់អ្នកជិតខាង




☛ ការចាប់ត្រីក្នុងស្រែទើបបាញ់ថ្នាំហើយ អាចគ្រោះថ្នាក់ដល់សុខភា



☛ ការយកធុងទៅលាង និងការបោះបង់សំបកដប ឬកំប៉ុងថ្នាំតាមត្រពាំង បឹង ស្ទឹង ឬទន្លេអាចនាំមកនូវគ្រោះថ្នាក់ដល់សត្វផ្សេងៗ ក៏ដូចមនុស្សយើងដែរ



☛ ការកប់សំបកដប ឬកំប៉ុងថ្នាំពុលដែលប្រើហើយអាចការពារបរិស្ថានភូមិយើង ក៏ដូចជាការពារគ្រោះថ្នាក់ផ្សេងៗ



សូមចៀសវាងការយកសំបកថ្នាំដែលប្រើរួចហើយ មកលាងទុកដាក់របស់អ្វីផ្សេងទៀត ទោះលាងយ៉ាងណាក៏ដោយវាមិនស្អាតដែរ



☛ ចៀសវាងកុំអោយក្មេងលេងសំបកដបថ្នាំ ឬកំប៉ុងថ្នាំដែលប្រើហើយ ព្រោះវាអាចប៉ះពាល់ដល់សុខភាពពួកគេ



☛ ការទុកដាក់ថ្នាំការពារដំណាំ អោយឆ្ងាយពីដៃក្មេង និងចំណីអាហារ អាចបន្ថយនូវភាពគ្រោះថ្នាក់ ដែលកើតឡើងជាយថាហេតុ






# សំណូមពរចុងក្រោយ

បន្ទាប់ពីអានកូនសៀវភៅនេះរួចមក ក្រុមអ្នកអ្នកនិពន្ធយើងខ្ញុំ ជឿជាក់ថា បងប្អូនកសិករច្បាស់ជាមានការយល់ច្បាស់បន្ថែមលើថ្នាំពុលនិងបញ្ហា ដែលបង្កឡើងតាមរយៈការប្រើប្រាស់ថ្នាំពុល ។ យើងខ្ញុំក៏សូមរំលឹកផងដែរថា គ្មានថ្នាំការពារដំណាំដែលមិនពុលទេ គ្រាន់តែកំរិតពុល និងរយៈពេលពុលរបស់វាខុសៗ គ្នាប៉ុណ្ណោះ។ ដូចនេះ សូមបងប្អូនកសិករធ្វើការពិចារណាអោយមែនទែនមុននឹងសំរេចចិត្តថាប្រើថ្នាំពុល ។ យកល្អ បងប្អូនគួជៀសវៀងប្រើវា ប្រសិនបើលោកអ្នកចង់ ឃើញគ្រួសាររស់នៅប្រកបដោយសុខភាពល្អដូចនេះ !



យើងខ្ញុំមិនចង់ឃើញ
លោកអ្នកជួបការលំបាក
ក្នុងបញ្ហាសុខភាព
របៀបនេះទេ !



ជាទីបញ្ចប់ ក្រុមអ្នកនិពន្ធយើងសូមអំពាវនាវអោយបងប្អូនកសិករនិងប្រជាពលរដ្ឋទាំងអស់ ចូលរួមចំណែកក្នុងការកាត់បន្ថយនូវភាពគ្រោះថ្នាក់ ដែលបង្កឡើងដោយសារថ្នាំពុល ជាពិសេសតាមរយៈការជួយពន្យល់បន្ត ក៏ដូចជាការបែងចែកកូនសៀវភៅនេះទៅអោយអ្នកដទៃទៀតអាន ។

**យើងរួមគ្នាកាត់បន្ថយគ្រោះថ្នាក់ ដោយសារថ្នាំពុលគីមី**
**ដើម្បីសុខភាព សេដ្ឋកិច្ចគ្រួសារ និងបរិស្ថាន**

# ឧបសម្ព័ន្ធៈ ថ្នាំដែលចៀសវាងប្រើ ឬប្រើក្នុងការប្រុងប្រយ័ត្នបំផុត

## តារាងទី ១ ៈថ្នាំពុលដែលពុលខ្លាំងបំផុតដល់មនុស្ស

| ល រ | ឈ្មោះរួម | ឈ្មោះពាណិជ្ជកម្ម | កសិករហៅ |
|---|---|---|---|
| ១ | ប្រូឌីហ្វាកូម ( Brodifacoum ) | ប្រូឌីហ្វា ( Brodifa ) | |
| ២ | កាបូហ្វុយរ៉ង់ ( Carbofuran) | ហ្វុយរ៉ាដង់ ( Furadan 3H/3G ) | ថ្នាំសត្វ |
| ៣ | មេទីលប៉ារ៉ាចុង(MethylParathion ) | ហ្វុសិនតុល ( Foxentol ) | |
| | | មេទីលប៉ារ៉ាចុង (MethylParathion 50EC ) | |
| | | ប៉ារ៉ាតែត ( Parathete ) | |
| | | អានគុនវ៉េ ( Ankun V ) | |
| | | ហ្វូលីដុល ( Folidol ) | ដេរ៉ាខៀវ |
| | | មេតាហ្វូស ( Methaphos 40 ND) | |
| | | ស៊ុយតុន អឹម ( Suthon M ) | |
| ៤ | មេវីនហ្វូស ( Mevinphos ) | បូសឌីន ( Bosdin) | |
| | | ហ្វៃទ័រ ( Fitor ) | ទង់ជ័យ |
| | | គីនផូស ២៤ ( K vinphos 24) | |
| | | ឡាក់ហ្វូស ( Lockphos ) | បាតដៃ |
| | | មេវីនហ្វូស ( Mevinphos 24 DD ) | |
| | | ហ្វូសឌ្រីន ( Phosdrin ) | ផ្លឹត |
| | | ស៊ុយឌ្រីន ( Sudrin ) | |
| ៥ | ម៉ូណូក្រូតូហ្វូស ( Monocrotophos ) | អាប៉ាឌ្រីន ( Apadrin ) | |
| | | អាសូឌ្រីន ( Azodrin 50DD ) | ទឹកមាត់ស្វា |
| | | អាសូឌ្រីន ( Azodrin 50 SCW ) | |
| | | វើលក្រុន ( Worldcron ) | |
| ៦ | មេតូមីល ( Methomyl ) | ឡេនណាត ( Lannat) | ឌុយប៉ុង |
| ៧ | មេតាមីដូហ្វូស ( Methamidophos) | ហ្វីលីតុក ( Filitox) | |
| | | ហ្វីលីតុក ( Filitox 50 EC) | |
| | | ហ្វីលីតុក ( Filitox 60 DD) | |

| | | | |
|---|---|---|---|
| | | ហ្វីលីតុក ( Filitox 70 SC) | |
| | | ជេន ( Giant) | |
| | | ជេន ( Giant 70 DD ) | |
| | | ម៉ារ៉ាថុន ( Marathon ) | |
| | | មេតាមីដូហ្វូស៧០%( Methamidiphos70% ) | |
| | | ម៉ូនីទ័រ ( Monitor 50 EC ) | ទឹកស្អុយ |
| | | ម៉ូនីទ័រ ( Monitor 50 SC ) | |
| | | ម៉ូនីទ័រ ( Monitor 50 DD ) | |
| | | អូវ៉ាន់ស៊ូ ( Ovansu) | |
| | | ថម ( Thom 50EC ) | |
| | | អ៊ុយ តេ ៧០ ( U T 70) | |
| | | វីន ដូ ( Vindo ) | |
| ៨ | ដាយក្លរ៉ូស (Dichlorvos ) | ដេ ដេ វេ ប៉េ ( DDVP ) | |
| | | ដេ ដេ វេ ប៉េ ៥០ អ៊ី សេ ( DDVP 50 EC ) | |
| | | ដេ ដេ វេ ប៉េ ៥០អិន ដេ ( DDVP 50 ND ) | |
| | | ដាយក្លរ៉ូស ( Dichlorvos ) | |
| | | វី ភី ៥០អ៊ីសេ ( V P 50 EC ) | |
| ៩ | មេទីដាថុង ( Methydathion ) | ស៊ុយប្រាស៊ីត (Supracide 40 ND) | |
| ១០ | ពីរីមីហ្វូសអេទីល ( Pyrimiphos- Ethyl) | អាកតេលីក ( Actellic 50 EC) | |
| ១១ | ហ្សាំងផូស្ពីត ( Zinc phospide ) | បេកខាំ ( Bek kham ) | |
| | | ហ្វូកេបា ២០% ( Fokeba 20 %) | |
| | | អូសូតស្ពា ( Osotspa) | |
| | | រាស័រ ( Razor 10 WP) | |
| | | តេ កា អូ ( T K O ) | ថ្នាំកណ្ដុរ |
| | | យូ អេស អេ ត្រា កង់តាល់ (USA Tra cantal) | |
| | | ហ្សាវ៉ា ( Zawa) | |
| | | ហ្សាំងផូស្វីត (Zinc phosphide20%) | |

## តារាងទី ២៖ ប្រភេទថ្នាំដែលពុលខ្លាំងបំផុតចំពោះត្រី

| ល.រ | ឈ្មោះរួម | ឈ្មោះពាណិជ្ជកម្ម | ឈ្មោះកសិករហៅ |
|---|---|---|---|
| ១ | ស៊ីពែមេទ្រីន ( Cypermethrin) | វីស៊័រ ( Visher 25 ND ) | |
| | | ស៊ីពេរីន ( Cyperin 10 EC) | |
| | | អារីវ៉ូ ( Arrivo 25 EC ) | |
| | | កាមេទ្រីន ( Camethrin 25 EC) | |
| | | ស៊ីមេរីន ( Cymerin 10EC ) | |
| | | ស៊ីមេរីន PSCL ( CymerinPSCL) | |
| | | ស៊ីពែមេទ្រីន (Cypermethrin 10 EC) | |
| | | ស៊ីប្រូអ៊ិត ( Cyproid 25EC) | |
| | | ស៊ីប្រូអ៊ិល ( Cyproil 25EC) | |
| | | ស៊ីរីន ( Cyrin 25 EC ) | |
| | | គូតនូត ១០ ( Kout nok 10 ) | |
| | | ប៊ែនប៊ែន ( Ben ben ) | |
| ២ | ដែលតាមេទ្រីន ( Delthamethrin) | ដេស៊ីស (Decis2.5 EC ) | |
| | | ខេ អូទ្រីន ( K- Othrin ) | |
| | | ដែលតាមេទ្រីន ( Deltamethrin) | |
| ៣ | ឌីក្លរ៉ូស (Dichlorvos ) | ដេ ដេ វេ ប៉េ ( DDVP ) | |
| | | ដេ ដេ វេ ប៉េ ៥០ អឺ សេ ( DDVP 50 EC ) | |
| | | ដេ ដេ វេ ប៉េ ៥០ អិន ដេ ( DDVP 50 ND ) | |
| | | ឌីក្លរ៉ូស ( Dichlorvos ) | |
| | | វេប៉េ ( V P 50 EC ) | |

| | | | |
|---|---|---|---|
| ៤ | អង់ដូស៊ុលហ្វង់ ( Endosulfan) | ទីយូដង់៣៥ អឺសេ ( Thiodan 35EC) | |
| | | ទីយូដង់ ( Thiodan 35ND) | |
| | | អង់ដូសុល (Endosol 35EC) | |
| ៥ | ក្លូពីរីហ្វូស ( Chlorpyrifos) | ពីរីណិច ( Pyrinex) | |
| ៦ | មេវីនហ្វូស ( Mevinphos ) | បូសឌីន ( Bosdin) | |
| | | ហ្វៃទ័រ ( Fitor ) | |
| | | ខេ វីនហ្វូស ២៤ ( K vinphos 24) | |
| | | ឡាក់ផូស ( Lockphos ) | |
| | | មេវីនហ្វូស (Mevinphos24DD ) | |
| | | ហ្វូសឌ្រីន ( Phosdrin ) | |
| | | ស៊ុយឌ្រីន ( Sudrin ) | |
| ៧ | ហ្ស៊ីនផូស្វីត ( Zinc phosphide ) | បេកខាំ ( Bek kham ) | |
| | | ហ្វូកេបា ២០% ( Fokeba20 %) | |
| | | អូសូតស្ពា ( Osotspa) | |
| | | រ៉ាស័រ ( Razor 10 WP) | |
| | | តេ កា អូ ( T K O ) | |
| | | យូអេសអេ ត្រា កង់តាល់ (USA Tra cantal ) | |
| | | ហ្សាវ៉ា ( Zawa) | |
| | | ហ្សាំងផូស្វីត ២០%( Zincphosphide 20 %) | |
| ៨ | ឌីយ៉ាស៊ីណុង ( Diazinon) | ឌីយ៉ាស៊ីណុង ( Diazinon 60EC) | |
| | | បាស៊ុយឌីន ( Basudin50 ND) | |
| | | កាស៊ីណុង (Cazinon 10H ) | |
| | | ជីហ្វាហ្គាល់ ( Gifagal) | |

**តារាងទី ៣៖ ប្រភេទថ្នាំពុលដែលពុលខ្លាំងផល់ឃ្មុំ**

| លរ | ឈ្មោះរួម | ឈ្មោះពាណិជ្ជកម្ម | កសិករហៅ |
|---|---|---|---|
| ១ | ស៊ីពែមេទ្រីន ( Cypermethrin) | វីស័រ ( Visher25 ND ) | ញីឈ្មោល |
| | | ស៊ីពែរីន ( Cyperin 10 EC) | |
| | | អារីវ៉ូ ( Arrivo 25 EC ) | |
| | | កាមេទ្រីន ( Camethrin 25 EC) | |
| | | ស៊ីមេរីន PSCL ( Cymerin PSCL ) | |
| | | ស៊ីពែរ៉ង់ ( Cyperan 10EC) | |
| | | ស៊ីពែរ៉ង់ ( Cyperan 25EC) | |
| | | ស៊ីពែមេទ្រីន (Cypermethrin 10 EC) | |
| | | ស៊ីប្រូអ៊ិត (Cyproid 25EC ) | |
| | | ស៊ីប្រូអ៊ិល ( Cyproil 25EC) | |
| | | ស៊ីរីន ( Cyrin 25 EC ) | |
| | | គូតនុត ១០ ( Kout nok 10 ) | |
| | | ប៊ែនប៊ែន ( Ben ben ) | |
| ២ | មេវីនហ្វូស ( Mevinphos ) | បូសឌីន ( Bosdine) | |
| | | ហ្វីទ័រ ( Fitor ) | ទង់ជ័យ |
| | | ខេ-វីនហ្វូស ២៤ ( K-vinphos 24) | |
| | | ឡុកហ្វូស ( Lockphos ) | បាតដៃ |
| | | មេវីនហ្វូស ( Mevinphos 24DD) | |
| | | ហ្វូសទ្រីន ( Phosdrin ) | ផ្លិត |
| | | ស៊ុយទ្រីន ( Sudrin ) | |

| | | | |
|---|---|---|---|
| ៣ | ឌីយ៉ាស៊ីណុង ( Diazinon) | ឌីយ៉ាស៊ីណុ ( Diazinon 60 EC) | |
| | | បាស៊ុយឌីន ( Basudin 50 ND ) | |
| | | កាស៊ីណុង ( Cazinon 10 H ) | |
| | | ជីហ្វាហ្កាល់ ( Gifagal) | |
| ៤ | ឌីក្លរ៉ូស (Dichlorvos ) | ដេ ដេ វេ ប៉េ ( DDVP ) | |
| | | ដេដេវេប៉េ ៥០អីសេ ( DDVP50EC ) | |
| | | ដេដេវេប៉េ ៥០អិនដេ(DDVP50ND ) | |
| | | ឌីក្លរ៉ូស ( Dichlorvos ) | |
| | | វេប៉េ ( V P 50 EC ) | |
| ៥ | ម៉ូណូក្រូតូហ្វូស ( Monocrotophos) | អាសូទ្រីន (Azodrin 50DD) | |
| | | អាសូទ្រីន (Azodrin50SC) | |
| | | អេឡុកស៊ីន (Elocsourn) | |
| | | ម៉ូណូក្រូតូហ្វូស ( Monocrotophos) | |
| | | តាន់កូទ្រីន ( Tanchodrin) | |
| | | អាប៉ាទ្រីន ( Apadrin) | |
| ៦ | មេតូមីល (Methomyl ) | ឡានណាត ( Lannate) | ឌុយប៉ុង |

**តារាងទី ៤ : ប្រភេទថ្នាំពុលដែលស្ថិតនៅក្នុងបរិស្ថានរយៈពេលយូរ (ថ្នាំដែលត្រូវសវាងប្រើជាពិសេសពួកលេខរៀងទី ១ ដល់ទី ៣)**

| លរ | ឈ្មោះរួម | ឈ្មោះពាណិជ្ជកម្ម | កសិករហៅ | រយៈពេលវាអស់ប្រសិទ្ធិភាព |
|---|---|---|---|---|
| ១ | ដេដេតេ ( DDT ) | ដេដេតេ ( DDT ) | | ៤-៣០ឆ្នាំ |
| ២ | ប៉ារ៉ាកាត ( Paraquate ) | ក្រាម៉ូសូន ( Gramoxone ) | | ២០០០ថ្ងៃ |
| ៣ | ក្លរដាន( Chlordane ) | ក្លរដាន ( Chlordane ) | | ៨ ឆ្នាំ |
| | | សាកេត វេ ៨៨ ( Sakate- V 88 ) | | |
| ៤ | កាបូហ្វុយរ៉ង់ ( Carbofuran) | ហ្វុយរ៉ាដង់ ( Furadan 3H ) | ថ្នាំសត្វ | ៦០-២៤០ថ្ងៃ |
| ៥ | ក្លពីរីហ្វូស ( Chlorpirifos) | ពីរីណិច ( Pyrinex) | | ១២០-២៤០ថ្ងៃ |
| ៦ | ស៊ីពែមេទ្រីន ( Cypermethrin) | វីស័រ ( Visher 25 ND ) | ញីឈ្មោល | ៦៤ -១១២ថ្ងៃ |
| | | ស៊ីពែរីន ( Cyperin 10 EC) | | |
| | | អារីវូ ( Arrivo 25 EC ) | | |
| | | កាមេទ្រីន (Camethrin 25 EC) | | |
| | | ស៊ីមេរីន ( Cymerin 10EC ) | | |
| | | ស៊ីមេរីន PSCL ( CymerinPSCL) | | |
| | | ស៊ីពែមេទ្រីន (Cypermethrin 10 EC) | | |
| | | ស៊ីប្រូអ៊ិត ( Cyproid 25EC) | | |
| | | ស៊ីប្រូអ៊ិល ( Cyproil 25EC ) | | |
| | | ស៊ីរីន ( Cyrin 25 EC ) | | |
| | | គូតនុត ១០ ( Kout nok 10 ) | | |

| | | | | |
|---|---|---|---|---|
| | | ប៊ែនប៊ែន ( Ben ben ) | | |
| ៧ | អង់ដូស៊ុលហ្វង់ ( Endosulfan) | ទីយូដង់ ( Thiodan 35EC) | | ១០០ថ្ងៃ |
| | | ទីយូដង់ ( Thiodan 35ND) | | |
| | | អង់ដូសុល (Endosol 35EC) | | |
| ៨ | គ្លីផូសេត ( Glyphosate ) | កាផូសេត ( Carphosate 480 SC) | | ៩៤ថ្ងៃ |
| | | គ្លីផូសង់ (Glyphosan 480 SC ) | | |
| | | ណូ ឡុង ៤៨ ( No- lon 48 ) | | |
| | | រ៉ោន អាប់ ( Round up ) | | |
| | | សាណូស ( Sanos ) | | |
| | | ស្បា ( Sbar ) | | |
| ៩ | ពែមេទ្រីន ( Permethrin) | ហ្វូលឃៀល ( Fullkill 50 EC) | | ៦០-៧៦ថ្ងៃ |
| | | ប៉ារាន ( Paran 50 EC) | | |
| | | អ៊ីមប៉ារ៉េតទ័រ (Imparator5EC ) | | |

# តារាងទី ៥ ៈបញ្ជីថ្នាំការពារដំណាំដែលមាននៅខេត្តកណ្តាល កំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង សៀមរាប និងកំពង់ធំ

| លរ | ឈ្មោះទូទៅ | ឈ្មោះពាណិជ្ជកម្ម | អំពើ | ចំណាត់ថ្នាក់តាមអង្គការសុខភាពពិភពលោក | ឈ្មោះកសិករហៅ |
|---|---|---|---|---|---|
| ១ | ? | 558 | សត្វល្អិត | | អំពូល |
| ២ | ? | ម៉ានីក្រូ (Marnicro) | ជំងឺផ្សិត | | |
| ៣ | ២.៤ ដេ (2.4-D) | ២.៤ ដេ សូឌីយូម សែល ( 2.4-D , Sodium salt) | ស្មៅ | ២ | |
| | | ៥០០ អាមីន ( 500 Amin ) | ស្មៅ | ២ | |
| | | អានកូ ( Anco 720 DD) | ស្មៅ | ២ | |
| | | កង់តូស៊ីន ( Cantosin 720DD) | ស្មៅ | ២ | |
| | | សេអូ ២.៤ដេ ( Co 2,4-D 80 BHN) | ស្មៅ | ២ | |
| | | វី ២.៤ដេ ( Vi 2.4-D 720DD) | ស្មៅ | ២ | |
| | | វី ២.៤ដេ៨០បេតេអិន ( Vi 2.4D 80 BTN) | ស្មៅ | ២ | |
| | | ហ្សាំងកូ ( Zico 720DD) | ស្មៅ | ២ | |
| | | ហ្សាំងកូ ( Zico 80BHN) | ស្មៅ | ២ | |
| | | ម៉េកប៉ូ ដេ Make po D | ស្មៅ | ២ | |
| | | ប៉ាតា ៨០ ( Pata 80) | ស្មៅ | ២ | |
| | | វីហាក់ អេស( Vihak S ) | ស្មៅ | ២ | |
| ៤ | អាឡាក្ល័រ (alachlor) | សាយឃីងសូ ( Sitekingso) | ស្មៅ | ៣ | |
| ៥ | អាល់ហ្វា ស៊ីពែមេទ្រីន (alpha cypermethrin) | ស៊ីពែអាល់ហ្វា ( Cyper-alpha 5ND) | សត្វល្អិត | ២ | |
| | | ហ្វាស់តុក ( Fastox 5EC) | សត្វល្អិត | ២ | |

| | | | | | |
|---|---|---|---|---|---|
| | | វីហ្វាស់ ( Vifast) | សត្វល្អិត | ២ | |
| | | សាប៉ង់អាល់ហ្វា ( Sapan alpha 5EC) | សត្វល្អិត | ២ | |
| ៦ | អាល់លុយមីញ៉ូមផូសហ្វីត (aluminium phosphide) | សែលហ្វូស ( Celphos) | សត្វល្អិត | ១.ក | |
| ៧ | បាក់ស៊ីលីសទុយរីចាំងស៊ីស (bacillus thurigiensis) | ដែលហ្វាំង ( Delfin WG) | សត្វល្អិត | ៣ | |
| | | ហ្វ័រវាប៊ីត( Forwabit 16.000IU) | សត្វល្អិត | ៣ | សង់ឌុំរកញ្ចប់ |
| | | ប៊ីយូប៊ីត ( Biobit 52 BFC) | សត្វល្អិត | ៣ | |
| | | ទុយរីសាយ ( Thuricide) | សត្វល្អិត | ៣ | |
| ៨ | ប្រូឌីហ្វាកូម (brodifacoum) | ប្រូឌីហ្វា ( Brodifa) | កណ្ដុរ | ១.ក | |
| ៩ | ប៊ុយប្រូហ្វេនហ្សាំង (buprofezin) | អាប្លូត ( Applaud 10 WP) | សត្វល្អិត ចៃ | ៣ | |
| ១០ | ប៊ុយតាក្ល័រ (butachlor) | មេកូ ( Meco 60EC) | ស្មៅ | ៣ | |
| ១១ | កាបារីល (carbaryl) | កាបារីល (95% Carbaril power) | សត្វល្អិត | ២ | |
| | | កាបារីល ( Carbaryl) | សត្វល្អិត | ២ | |
| | | កាបារីល ( Carbaryl 85BTN) | សត្វល្អិត | ២ | |
| ១២ | កាបង់ដាហ្ស៊ីម (carbendazim) | អាប់ផែនកាប ស៊ុបពែ ( Appencarb super 50 FL) | ជំងឺផ្សិត | ៣ | |
| | | បាវីសទីន ( Bavistin FL) | ជំងឺផ្សិត | ៣ | |
| | | កាបែនដា ( Carbenda 50SC) | ជំងឺផ្សិត | ៣ | |
| | | កាបែនវីល ( Carbenvil 50SC) | ជំងឺផ្សិត | ៣ | |
| | | ដេរ៉ូសល ( Derosal 50SC) | ជំងឺផ្សិត | ៣ | |
| | | វីកាបែន ( Vicarben 50HP) | ជំងឺផ្សិត | ៣ | |

| | | | | | |
|---|---|---|---|---|---|
| ១៣ | កាបូហ្វុយរ៉ង់ (carbofuran) | ហ្វុយរ៉ាដង់ (Furadan 3 H) | សត្វល្អិត ចៃ ណេម៉ាតូត | ១.ខ | ថ្នាំសត្វ |
| | | ហ្វុយរ៉ា (Furadan 3G) | សត្វល្អិត ចៃ ណេម៉ាតូត | ១.ខ | ថ្នាំសត្វ |
| | | កូរ៉ាត (Korathe 3%) | សត្វល្អិត ចៃ ណេម៉ាតូត | ១.ខ | |
| | | ការាដង់ (caradan 5H) | សត្វល្អិត ចៃ ណេម៉ាតូត | ១.ខ | |
| ១៤ | កាតាប (cartap) | ប៉ាដង់ (Padan 95 SP) | សត្វល្អិត | ២ | ប៉ាតង់ |
| ១៥ | ក្លរដាន (chlordane) | ក្លូ ដាន (Chlordane) | សត្វល្អិត | ២ | |
| | | សាកេត (Sakete-V 88) | សត្វល្អិត | ២ | |
| ១៦ | ក្លរភ្លុយអាហ្សុយរ៉ុង (chlorfluazuron) | អាតាប្រុង ( Atabron 5EC) | សត្វល្អិត | ៣ | |
| ១៧ | ក្លរពីរីហ្វូស (chlorpyrifos) | ពីរីណិច ( Pyrinex 2EC) | សត្វល្អិត | ២ | |
| ១៨ | កូពៃ អុកស៊ីក្លូរីត (copper oxychloride) | គុយប្រាវីត ( Cupravit) | ជំងឺផ្សិត | ៣ | |
| ១៩ | ស៊ីពែមេទ្រីន (cypermethrin) | អារីវ៉ូ ( Arrivo 25EC) | សត្វល្អិត | ២ | |
| | | កាម៉េទ្រីន( Carmethrin 25 EC) | សត្វល្អិត | ២ | |
| | | ស៊ីលឃើ ១០ (Silker 10 ) | សត្វល្អិត | ២ | |
| | | តង់ស្ហ៊ូ (Tenzo) | សត្វល្អិត | ២ | |
| | | ស៊ីមេរីន ( Cymerin 10EC) | សត្វល្អិត | ២ | |
| | | ស៊ីមេរីន ( Cymerin PSCL) | សត្វល្អិត | ២ | |
| | | ស៊ីមេរាន ( Cyperan 10EC) | សត្វល្អិត | ២ | |
| | | ស៊ីមេរាន (Cyperan 25EC) | សត្វល្អិត | ២ | |
| | | ស៊ីពើរីន (Cyperin10 EC) | សត្វល្អិត | ២ | |

| | | | | | |
|---|---|---|---|---|---|
| | | ស៊ីពែមេទ្រីន (Cypermethrin 10EC) | សត្វល្អិត | ២ | |
| | | ស៊ីប្រូអ៊ីត (Cyproid 25%EC) | សត្វល្អិត | ២ | |
| | | ស៊ីប្រូអ៊ីល( Cyproil 25% EC) | សត្វល្អិត | ២ | |
| | | ស៊ីរីន (Cyrin 25 EC) | សត្វល្អិត | ២ | |
| | | កៅណុក ១០ (Koutnok 10) | សត្វល្អិត | ២ | |
| | | វៃស័រ (Visher 25 ND) | សត្វល្អិត | ២ | ហ្សេតបា |
| | | ប៉ែនប៉ែន (benben 50EC ) | សត្វល្អិត | ២ | |
| ២០ | ស៊ីប្រូកូសុល (cyprocozole) | បូណង់សា (Bonanza) | ផ្សិត | ៣ | |
| ២១ | ដេដេតេ (DDT) | ដេដេតេ (DDT) | សត្វល្អិត | ២ | |
| ២២ | ដែលតាមេទ្រីន (deltamethrin) | ដេស៊ីស (Decis 2.5EC) | សត្វល្អិត | ២ | |
| | | ដែលតាមេទ្រីន (Deltamethrin) | សត្វល្អិត | ២ | |
| | | កា អូទ្រីន (K-othrine) | សត្វល្អិត | ២ | |
| ២៣ | ឌីយ៉ាហ្វែនទីយូរ៉ុង (diafenthiuron) | ប៉េកាស៊ូស (Pegasus 500DD) | សត្វល្អិត ចៃ | ៣ | ធៀប |
| ២៤ | ឌីយ៉ាហ្សីណុង (diazinon) | បាស៊ុយឌីន (Basudin 50ND) | សត្វល្អិត កណ្ដុរ ណេមាតូត | ២ | |
| | | កាស៊ីណុង (Cazinon 10H) | សត្វល្អិត ណេមាតូត | ២ | |
| | | ឌីយាស៊ីណុង (Diazinon 60EC) | សត្វល្អិត ណេមាតូត | ២ | |
| | | ជីហ្វាហ្គាល់ (Gifagal) | សត្វល្អិត កណ្ដុរ ណេមាតូត | ២ | |
| ២៥ | ឌីក្លរ៉ូវ៉ស (dichlorvos) | ដេដេវៃប៉េ (DDVP) | សត្វល្អិត ចៃ | ១.ខ | |
| | | ដេដេវៃប៉េ ៥០អ៊ីសេ (DDVP 50 EC) | សត្វល្អិត ចៃ | ១.ខ | |

| | | | | | |
|---|---|---|---|---|---|
| | | ដេដេវ៉េប៉េ៥០អិនដេ (DDVP 50ND) | សត្វល្អិត ថៃ | ១.ខ | |
| | | ដេដេវ៉េប៉េ៥០អិនដេ (DDVP 50ND) | សត្វល្អិត ថៃ | ១.ខ | |
| | | ឌីក្លរូវស (Dichlorvos) | សត្វល្អិត ថៃ | ១.ខ | ដំរី |
| | | វីភី ៥០អីសេ( VP 50EC) | សត្វល្អិត ថៃ | ១.ខ | |
| | | ឌីនៀរ (Dinear) | សត្វល្អិត ថៃ | ១.ខ | |
| ២៦ | ឌីមេអ៊ីប៉ូ dimehypo (nereistoxin) | ហ្សា ជុង ដសម ផូវើរ ( 90 % Sha Chong Dan Power) | សត្វល្អិត | ២ | |
| | | ៩៥ ដាបបែលយូភី (95 WP) | សត្វល្អិត | ២ | |
| | | ហ្សាជុងហ្សាង ( Shachongshuang 95 WP) | សត្វល្អិត | ២ | ប៉ាតង់លេខពីរ |
| | | ហែបភើរ ( Helper 5G) | សត្វល្អិត | ២ | |
| | | ណេតុកស៊ីន ( Netoxin 18SL/DD) | សត្វល្អិត | ២ | |
| | | ណេតុកស៊ីន ( Netoxin 18WP) | សត្វល្អិត | ២ | |
| ២៧ | ឌីមេតូអាត (dimethoate) | បាសូកា ( Basoca) | សត្វល្អិត ថៃ | ២ | |
| | | ប៊ី អាយ ( BI 58 40EC) | សត្វល្អិត ថៃ | ២ | |
| | | ប៊ីអេន ( BiAn 40ND) | សត្វល្អិត ថៃ | ២ | |
| | | ឌីបាតូត ( Dibathote 40 EC) | សត្វល្អិត ថៃ | ២ | |
| | | ឌីមេណាត ( Dimenate 40EC) | សត្វល្អិត ថៃ | ២ | |
| | | ហ្វាមតយ ( Famtoy) | សត្វល្អិត ថៃ | ២ | |
| | | លុយសិនម៉េត ( Luxenmet 40) | សត្វល្អិត ថៃ | ២ | |
| | | វីឌីតូអាត ( Vidithoate 40ND) | សត្វល្អិត ថៃ | ២ | |
| ២៨ | ឌីមេតូអាត + ហ្វេនណូប៊ុយកាប (dimethoate+fenobucarb) | បេបេ ទីជី ( BB-tigi 5H) | សត្វល្អិត ថៃ | ២ | |

| | | | | | |
|---|---|---|---|---|---|
| ២៩ | ឌីទីអូកាបាម៉ាត (dithiocarbamates) | ហ្ស៊ីណេប ( Zineb) | ជំងឺផ្សិត | ៣ | |
| ៣០ | អង់ដូស៊ុលហ្វង់ (endosulfan) | អង់ដូសុល ( Endosol 35EC) | សត្វល្អិត ចៃ | ២ | |
| | | សូនី ( Sonii ) | សត្វល្អិត ចៃ | ២ | |
| | | ទីយូដង់ ( Thiodan) | សត្វល្អិត ចៃ | ២ | |
| | | ទីយូដង់ ( Thiodan 35EC) | សត្វល្អិត ចៃ | ២ | កូរស្រូវ |
| | | ទីយូដង់ ( Thiodan 35ND) | សត្វល្អិត ចៃ | ២ | ពោត |
| ៣១ | អេតូហ្វេនប្រុក (ethofenprox) | ត្រេបុង (Trebon10EC) | សត្វល្អិត | ៣ | |
| ៣២ | ហ្វេននីត្រូចុង + ទ្រីក្ល័រហ្វុង (fenitrothion+trichlorfon) | អូហ្វូតុក ( Ofotox 400EC) | សត្វល្អិត ចៃ | ២+៣ | |
| ៣៣ | ហ្វេណូប៊ុយកាប (fenobucarb) | បាសសា ( Basa 50ND) | សត្វល្អិត | ២ | |
| | | បាសស៊ីត ( Bascide 50EC) | សត្វល្អិត | ២ | |
| | | បាសសា (Bassa 50EC) | សត្វល្អិត | ២ | |
| | | បាសសង់ ( Bassan 50EC) | សត្វល្អិត | ២ | |
| | | បាសសាទីជី ( Bassatigi 50ND) | សត្វល្អិត | ២ | |
| ៣៤ | ហ្វេណូប៊ុយកាប + ឌីមេតូអាត (fenobucarb+dimethoate) | វីបាម ( Vibam 5H) | សត្វល្អិត | ២ | |
| ៣៥ | ហ្វេនណូសាប្រុប ប៉េ អេទីល (fenoxaprop-P-ethyl) | វីប ( Whip S 75EW) | ស្មៅ | ៣ | |
| ៣៦ | ហ្វេនវ៉ាល់លើរ៉េត (fenvalerate) | ហ្វេនឃៀល ( Fenkill 20EC) | សត្វល្អិត | ២ | |
| | | ហ្វឺស (First 20EC) | សត្វល្អិត | ២ | |
| | | ហ្សាស៊ីស៊ីឌីន ( Shasicidine) | សត្វល្អិត | ២ | |
| | | ស៊ុយមីស៊ីឌីន( Sumicidin 20EC) | សត្វល្អិត | ២ | |
| | | វីបាសា ( Vibasa 50ND) | សត្វល្អិត | ២ | |
| | | វីហ្វេនវ៉ា (Vifenva 20 ND) | សត្វល្អិត | ២ | ញីឈ្មោល |

| | | | | | |
|---|---|---|---|---|---|
| ៣៧ | ហ្វេនវ៉ាល់លើរ៉េត +ផូសហ្វាមីដុង (fenvalerate+phosphamidon) | អិច កា ( XK-35EC) | សត្វល្អិត | ២+១.ក | |
| ៣៨ | ហ្វេនវ៉ាល់លើរ៉េត + ឌីមេតូអាត (fenvalerate+dimethoat) | ហ្វេនប៊ីស ( Fenbis 25 EC) | សត្វល្អិត | ២ | |
| ៣៩ | ហ្វីប្រូនីល (fipronil) | រីជិន ( Regent 50SC) | សត្វល្អិត | ២ | តុក្កតា |
| | | រីជិន ( Regent 50SC) | សត្វល្អិត | ២ | ស្លែ |
| | | រីជិន ( Regent 800WG) | សត្វល្អិត | ២ | តុក្កតា |
| ៤០ | ហ្វីប្រូនីល+ហ្វេនវ៉ាលឡឺរេត+ ហ្វូហ្វាមីដុង(fipronil+fenvale rat + phophamidon) | រីហ្វង់ ( Refent) | ថៃ និង សត្វល្អិត | ១.ក+២ | |
| ៤១ | ភ្លុយហ្វេណូស៊ុយរ៉ុង (flufenoxuron) | កាសកាត ( Cascade 5EC) | សត្វល្អិត | ៣ | |
| ៤២ | ហ្វូលភីត (folpet) | ហ្វូលផេន ( Folpan) | ជំងឺផ្សិត | ៣ | |
| ៤៣ | គ្លីផូសេត (glyphosate) | កាហ្វូសេត ( Carphosate 480SC) | ស្មៅ | ៣ | |
| | | គ្លីផូសង់ ( Glyphosan 480 DD) | ស្មៅ | ៣ | |
| | | លុកសានផូសេត ( Lucsanphosate) | ស្មៅ | ៣ | |
| | | គ្លីផូសេត ៤៨ (glyphosat 48) | ស្មៅ | ៣ | |
| | | អ៊ុយហ្វូអាប់ (Uphoup48) | ស្មៅ | ៣ | |
| | | ណូ ឡុង ៤៨ (No-lon 48) | ស្មៅ | ៣ | |
| | | រោន អាប់ (Round up) | ស្មៅ | ៣ | |
| | | សាណូស ( Sanos) | ស្មៅ | ៣ | |
| | | ស្បា (Sbar) | ស្មៅ | ៣ | |
| ៤៤ | អ៊ិសាកូណាសុល hexaconazole | អានវីល (Anvil 5SL) | ផ្សិត | ៣ | |

| | | | | | |
|---|---|---|---|---|---|
| ៤៥ | អ៊ីប្រូឌីយ៉ូន iprodione | រ៉ូវ រ៉ាល (Rovral 50 WP) | ផ្សិត | ៣ | |
| ៤៦ | អ៊ីសូប្រូកាប isoprocarb | វីមីប (Vimipc 20 ND) | សត្វល្អិត | ២ | |
| ៤៧ | ឡាមដា ស៊ីអាឡូទ្រីន lambda-cyhalothrin | ការ៉ាត (Karate 2.5 EC) | សត្វល្អិត | ២ | |
| ៤៨ | លុយហ្វេនយូរ៉ុង lufenuron | ម៉ាត (Match 50ND) | សត្វល្អិត | ២ | |
| ៤៩ | ម៉ង់កូហ្សេប mancozeb | បូស ( Bos) | ជំងឺផ្សិត | ៣ | |
| | | ថេន អឹម (Ten M) | ជំងឺផ្សិត | ៣ | |
| | | ប៉ែនកូហ្សេប ( Penncozeb) | ជំងឺផ្សិត | ៣ | |
| | | ឌីហ្សេប ដេ (Dizeb-D) | ជំងឺផ្សិត | ៣ | |
| | | អាហ្សីនម៉ាក (Azinmag) | ជំងឺផ្សិត | ៣ | |
| ៥០ | ម៉ង់កូហ្សេប + មេតាឡាក់ហ្ស៊ីល mancozeb+metalaxyl | រីដូមីល (Ridomil MZ 72 BHN) | ជំងឺផ្សិត សត្វល្អិត | ៣+១.ក | |
| ៥១ | មេតាមីដូហ្វូស methamidophos | ហ្វីលីតុក (Filitox) | សត្វល្អិត ចៃ | ១.ខ | |
| | | ហ្វីលីតុក (Filitox 50EC) | សត្វល្អិត ចៃ | ១.ខ | |
| | | ហ្វីលីតុក (Filitox 60DD) | សត្វល្អិត ចៃ | ១.ខ | |
| | | ហ្វីលីតុក (Filitox 70SC) | សត្វល្អិត ចៃ | ១.ខ | |
| | | ជេន (Giant) | សត្វល្អិត ចៃ | ១.ខ | |
| | | ជេន (Giant 70DD) | សត្វល្អិត ចៃ | ១.ខ | |
| | | ម៉ារ៉ាតុន (Marathon) | សត្វល្អិត ចៃ | ១.ខ | |
| | | មេតាមីដូហ្វូស (Methamidophos 70 %) | សត្វល្អិត ចៃ | ១.ខ | ម៉ូទ័រ |
| | | ម៉ូនីទ័រ (Monitor 50EC) | សត្វល្អិត ចៃ | ១.ខ | ទឹកស្អុយ |
| | | ម៉ូនីទ័រ ៥០ អេសសេ (Monitor 50SC) | សត្វល្អិត ចៃ | ១.ខ | ទឹកស្អុយ |
| | | ម៉ូនីទ័រ ៧០ដេដេ (Monitor 70DD) | សត្វល្អិត ចៃ | ១.ខ | ទឹកស្អុយ |

| | | | | | |
|---|---|---|---|---|---|
| | | អូវ៉ាន់ស៊ូ (Ovansu) | សត្វល្អិត ថៃ | ១.ខ | |
| | | ថម (Thom 50EC) | សត្វល្អិត ថៃ | ១.ខ | |
| | | អ៊ុយ តេ ៧០ (U-T 70) | សត្វល្អិត ថៃ | ១.ខ | |
| | | វីនដូ (Vindo) | សត្វល្អិត ថៃ | ១.ខ | |
| ៥២ | មេទីដាធុង **(methidathion)** | ស៊ុយប្រាស៊ីត(Supracide4 0ND) | សត្វល្អិត ថៃ | ១.ខ | ក្រាហ៊ុយ |
| ៥៣ | មេតូមីល **(methomyl)** | ឡានណាត (Lannat) | សត្វល្អិត | ១.ក | |
| ៥៤ | មេទីលប៉ារ៉ាធុង **( methyl parathion)** | ហ្វូសិនតុល (Foxentol) | សត្វល្អិត ថៃ | ១.ក | |
| | | មេទីលប៉ារ៉ាធុង (Methylparathion 50EC) | សត្វល្អិត ថៃ | ១.ក | |
| | | ប៉ារ៉ាថេត (Parathet) | សត្វល្អិត ថៃ | ១.ក | |
| | | អានគុណ -វី (Ankun-V) | សត្វល្អិត ថៃ | ១.ក | |
| | | ហ្វូលីដុល (Folidol) | សត្វល្អិត ថៃ | ១.ក | ដេរ៉ា |
| | | មេតាហ្វូស (Metaphos 40ND) | សត្វល្អិត ថៃ | ១.ក | |
| | | ស៊ុយតុន អឹម (Suthon-M) | សត្វល្អិត ថៃ | ១.ក | |
| | | ហ្វូលេ-ហ្វូលេ (Folez-Folez) | សត្វល្អិត ថៃ | ១.ក | |
| | | អេលស៊ីដុលដេ (Elxydol-D) | សត្វល្អិត ថៃ | ១.ក | |
| | | ទ្រីតុក (Treetox) | សត្វល្អិត ថៃ | ១.ក | |
| | | ប៉ាម៉ាកុង (Pamacon) | សត្វល្អិត ថៃ | ១.ក | |
| | | អែលស៊ីលដុល (Elxyldol-D) | សត្វល្អិត ថៃ | ១.ក | |
| | | វ៉ាលីដុល វេ (Validol- V) | សត្វល្អិត ថៃ | ១.ក | |
| | | ហ្វូលីដុល (Folidol 358) | សត្វល្អិត ថៃ | ១.ក | |
| ៥៥ | មេស៊ុលហ្វុយរ៉ុងមេទីល + ក្លរីមុយរ៉ុងអេទីល **(metsulfuron methyl + chlorimuron ethyl)** | អាល់មិច (Almix 20WP) | ស្មៅ | ៣ | |
| ៥៦ | មេវីនហ្វូស **(mevinphos)** | បូសឌីន (Bosdin) | សត្វល្អិត ថៃ | ១.ក | សេកា |

| | | | | | |
|---|---|---|---|---|---|
| | | ហ្វៃទ័រ (Fitor) | សត្វល្អិត ថៃ | ១.ក | ទង់ជ័យ |
| | | គ្វីនផូស (Kvinphos 24) | សត្វល្អិត ថៃ | ១.ក | |
| | | ឡុកផូស (Lockphos) | សត្វល្អិត ថៃ | ១.ក | បាតដៃ |
| | | មេវីនផូស (Mevinphos 24DD) | សត្វល្អិត ថៃ | ១.ក | ផ្លិត |
| | | ផូសទ្រីន (Phosdrin) | សត្វល្អិត ថៃ | ១.ក | |
| | | ស៊ុយទ្រីន (Sudrin) | សត្វល្អិត ថៃ | ១.ក | |
| | | អ៊ិច ហ្វូស (X-phos) | សត្វល្អិត ថៃ | ១.ក | |
| | | ហ្វូស គិន (Phoskin) | សត្វល្អិត ថៃ | ១.ក | |
| | | ហ្វាមូសូ (Famoso240) | សត្វល្អិត | ១.ក | |
| ៥៧ | ម៉ូណូក្រូតូហ្វូស **(monocrotophos)** | អាប៉ាទ្រីន (Apadrin) | សត្វល្អិត ថៃ | ១.ខ | |
| | | អាសូទ្រីន (Azodrin 50 DD) | សត្វល្អិត ថៃ | ១.ខ | អាសូទ្រីន |
| | | អាសូទ្រីន (Azodrin 50 SCW) | សត្វល្អិត ថៃ | ១.ខ | អាសូទ្រីន |
| | | វលក្រុន (Worldcron) | សត្វល្អិត ថៃ | ១.ខ | សូទ្រីន |
| | | ម៉ូណូក្រូតូហ្វូស (Monocrotophos) | សត្វល្អិត ថៃ | ១.ខ | កាកស្លា |
| | | តានចូទ្រីន (Tanchodrine) | សត្វល្អិត ថៃ | ១.ខ | |
| ៥៨ | អូមេតូអាត **(omethoate)** | ហ្សូនី (Zony) | សត្វល្អិត ថៃ | ១.ខ | |
| | | ហ្វូល ធូល ( Folk tool) | សត្វល្អិត ថៃ | ១.ខ | |
| | | អូមេតូអាត (Omethoate) | សត្វល្អិត | ១.ខ | |
| ៥៩ | ប៉ារ៉ាកាត **(paraquat)** | ក្រាម៉ូសូន (Gramoxone) | ស្មៅ | ២ | |
| ៦០ | ប៉ារាកាត ឌិក្លរីត **(Paraquate dichloride)** | ហ្វូកុង (Phokon) | ស្មៅ | ២ | |
| ៦១ | ពែមេទ្រីន **(permethrin)** | ហ្វូលឃៀល (Fullkill 50EC) | សត្វល្អិត | ២ | |
| | | អ៊ីមពែរេទ័រ (Imperator 50 EC) | សត្វល្អិត | ២ | |

| | | | | | |
|---|---|---|---|---|---|
| | | ពែរ៉ង់ (Peran 50 EC) | សត្វល្អិត | ២ | |
| | | អ៊ីមពែរទ័រ (Imperator 50 EC) | សត្វល្អិត | ២ | |
| ៦២ | ហ្វេនតូអាត (phenthoate) | វីហ្វេល (Vifel 50ND) | សត្វល្អិត ចៃ | ២ | ញីឈ្មោល |
| ៦៣ | ហ្វេនតូអាត + អេតូហ្វេនប្រុក (phenthoate+etofenprox) | វីស៊ីឌី (vicidi M 50 ND) | សត្វល្អិត ចៃ | ២+៣ | |
| ៦៤ | ហ្វេនតូអាត + ហ្វេនណូប៊ុយកាប (phenthoate+ fenobucarb) | ហប់សង់ ៧៥ (Hopsan75) | សត្វល្អិត | ២ | |
| ៦៥ | ពីរីមីហ្វូស អេទីល (pirimiphos-ethyl) | អាកតែលីក (Actellic 50EC) | សត្វល្អិត | ១.ខ | |
| ៦៦ | ប្រូហ្វេនណូហ្វូស (profenofos) | សេឡិចក្រុង (Selecron 500DD) | សត្វល្អិត | ២ | |
| ៦៧ | ប្រូប៉ាជីត (propargite) | កូមីត (Comite 73EC) | ចៃ | ៣ | |
| ៦៨ | ប្រូពីកូណាហ្សុល (propiconazole | ទីល (Tilt 250 ND) | ជំងឺផ្សិត | ២ | ទិន |
| ៦៩ | ប្រូពីកូណាហ្សុល+ ឌីហ្វេនណូកូណា សុល (propiconazole +difenoconazole ) | ទីលស៊ុពែ (Tilt super 300EC) | ជំងឺផ្សិត | ២+៣ | |
| ៧០ | សេតូស៊ីឌីម (sethoxydim) | ណាប៊ុស (Nabus 12.5EC) | ស្មៅ | ៣ | |
| ៧១ | ស្ត្រេបតូមីស៊ីន ស៊ុលផាត streptomycin sulphate | អេនទីបាស (Antibac) | ជំងឺបាក់តេរី | ៣ | |
| ៧២ | តេប៊ុយហ្វេណូហ្សីត (tebufenozale) | មីមិក ( Mimic 20F) | សត្វល្អិត | ៣ | |
| ៧៣ | ទីយូផាណាត មេទីល (thiophanate-methyl) | ប៊ីនស៊ីន (Binhsin 70 WP) | ជំងឺផ្សិត | ៣ | |
| | | តុបស៊ីន (Topsin-M 70 WP) | ជំងឺផ្សិត | ៣ | |
| | | មេទីអាត (Methyate 70WP) | ជំងឺផ្សិត | ៣ | |
| | ធីយ៉ូយូរេ ( Thiourea ) | ធីយ៉ូយូរេ ( Thiourea ) | ជំងឺបាក់តេរី | ១.ក | |
| ៧៤ | វ៉ាលីដាមីស៊ីន (validamycin) | វ៉ាលីដាស៊ីន (Validacin 5SP) | ជំងឺផ្សិត | ៣ | |

| | | | | | |
|---|---|---|---|---|---|
| | | វ៉ាលីដាមីស៊ីន (Validamycin A 3%) | ជំងឺផ្សិត | ៣ | |
| | | វ៉ាលីដាន (Validan 3L) | ជំងឺផ្សិត | ៣ | |
| | | វីមិច (Vimix 13.1 DD) | ជំងឺផ្សិត | ៣ | |
| | | វីវ អាដាមី (Viv adamy 3DD) | ជំងឺផ្សិត | ៣ | |
| ៧៥ | វីរុស-បាក់ស៊ីលីសទុយរីជេនីស៊ីស **(Virus+bacillus hurigienesis)** | វី ប៊ីធី (V-BT) | សត្វល្អិត | ២ | |
| ៧៦ | ហ្សាំងផូស្វីត **(zinc phospide)** | បេកខាំ (Bek kham) | កណ្ដុរ | ១.ខ | |
| | | ហ្វូកេបា (Fokeba 20%) | កណ្ដុរ | ១.ខ | |
| | | អូសូស្ប៉ា (Osotspa) | កណ្ដុរ | ១.ខ | |
| | | រ៉ាស័រ (Razor 10WP) | កណ្ដុរ | ១.ខ | |
| | | ធី ឃេ អូ (T-K-O) | កណ្ដុរ | ១.ខ | ថ្នាំកណ្ដុរ |
| | | អ៊ុសាត្រាកុងតាល់ (Usa tra cantal) | កណ្ដុរ | ១.ខ | |
| | | ហ្សាវ៉ា (Zawa) | កណ្ដុរ | ១.ខ | |
| | | ហ្សាំង ផូស្វីត (Zinc phosphide) | កណ្ដុរ | ១.ខ | |
| | | ហ្សីផូស (Zinphos 20%) | កណ្ដុរ | ១.ខ | |
| | | ម៉ាមីម៉ៅ (mummymouse) | កណ្ដុរ | ១.ខ | |
| | | គេ ភី វី (K-P-V) | កណ្ដុរ | ១.ខ | |
| | | មីសែល ( Mi-shell) | កណ្ដុរ | ១.ខ | |
| ៧៧ | ហ្ស៊ីនណេប **(zineb)** | សាក់ តេ កុប សាយ (Sake Te kop say V 80) | ផ្សិត | ៣ | |
| | | ហ្សាំង (Zin 80WP) | ផ្សិត | ៣ | |

# ឯកសារពិគ្រោះ


១. ស៊ី វ៉ាមុនី សុន ដារា និងទៀវ វិសុទ្ធ : យល់ដឹងដើម្បីសុខភាព និងបរិស្ថាន កម្មវិធីអប់រំអំពីការប្រើប្រាស់ថ្នាំពុលកសិកម្ម សហការរៀបចំដោយក្រសួងបរិស្ថាន និងគំរោងគ្រប់គ្រងបរិស្ថានកម្ពុជា (ឯកសារ មិនមានបញ្ជាក់ពីឆ្នាំបោះពុម្ពផ្សាយ)

២. យ៉ង សាំងកុមារ គាម មករាឌី និង ឡាង សេងហ៊ង (២000) : របាយការណ៍ទីផ្សារថ្នាំពុលនៅខេត្តកណ្ដាល បោះពុម្ពដោយមជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

៣. Jan H.Oudejans (1991): Agro-pesticides, Properties and Functions in Integrated Crop Protection, revised edition បោះពុម្ពដោយ ESCAP/UN

៤. CDS Tomlin (1998): The Pesticide Manual, A World Compendium បោះពុម្ពដោយ British Crop Protection

៥. David Bull (1982): A growing Problem, Pesticides and the Third World Poor បោះពុម្ពដោយ Oxfam

៦. Extoxnet (1996): Pesticide Information Profiles ឯកសារផ្សព្វផ្សាយតាម ប្រពន្ធ័ Internet របស់ Extoxnet

៧. Gregg Strong (1998) : Breaking the Silence, Plantations & Pesticides, បោះពុម្ពដោយ Pesticide Action Network Asia and the Pacific (PAN AP)

៨. Gretta Goldeman និង Sarojini Rengam (1989) : Pesticides and You, 44 Questions and Answers បោះពុម្ពដោយ IOCU (International Organization of Consumers Unions )

៩. GIFAP (1989) : Guidelines for the Safe and Effective use of Pesticides

១០. Helen Murphy (1997) : The Health Effects of Pesticide Use : Methods to conduct Community Studies with School Age Children ឯកសារពង្រាងសំរាប់អង្គការ World Education

១១. Miller, G-Tyler(1993): Environmental Science/ បោះពុម្ពលើទី ៤, Wadsworth, Inc.

១២. R-T. Meister (1999) : Farm Chemicals Handbook's, Meister Publishing Company

១៣. The Third World Network (1990): ការវិលត្រឡប់មករកផែនដីដ៏ល្អវិញ (Return to the good earth).

១៤. Wilina Arendse និង អ្នកនិពន្ធផ្សេងៗទៀត (1995) : Pesticides Compounds, Use and Hazards (Agrodok 21) បោះពុម្ពផ្សាយដោយ Agromisa

## មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (ម.ស.អ.ក ឬ CEDAC)

មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ជាអង្គការមិនមែនរដ្ឋាភិបាលខ្មែរ ឯករាជ្យ មិនគិតប្រាក់ចំណេញ និងមិនពាក់ពន្ធ័នយោបាយ ។ មជ្ឈមណ្ឌល ត្រូវបានបង្កើតឡើងនៅខែសីហា ឆ្នាំ ១៩៩៧ ក្នុងគោលបំណងចូលរួមចំណែកអភិវឌ្ឍន៍កសិកម្មជាលក្ខណៈគ្រួសារ និងពង្រឹងសមត្ថភាពសហគមន៍ក្នុងការថែរក្សាធនធានធម្មជាតិ

ដើម្បីសំរេចបាននូវទស្សនៈ និងបេសកម្មរបស់ខ្លួន មជ្ឈមណ្ឌលបាននិងកំពុងអនុវត្តន៍នូវកម្មវិធីជាច្រើន ដូចជា : ការងារផ្សព្វផ្សាយកសិកម្ម ការងារស្រាវជ្រាវនិងអប់រំអំពីបញ្ហាថ្នាំពុលគីមី ការងារបណ្តុះបណ្តាលផ្នែកកសិកម្មនិងអភិវឌ្ឍន៍សហគមន៍ តំកល់ឯកសារ និងបោះពុម្ពផ្សាយ ពង្រឹងសមត្ថភាពអ្នកកសិកម្មវ័យក្មេង និងពង្រឹងបណ្តាញការងារ ។

## គំរោងកាត់បន្ថយការបំពុលបរិស្ថាន និងគ្រោះថ្នាក់ដល់សុខភាពតាមរយៈ ការប្រើប្រាស់ថ្នាំពុល នៅជុំវិញបឹងទន្លេសាប

បញ្ហាគ្រោះថ្នាក់ដល់បរិស្ថាន សុខភាព និរន្តរភាពនៃអាជីវកម្មជាលក្ខណៈគ្រួសារនៅកម្ពុជា តាមរយៈការប្រើថ្នាំពុលខុសរបៀបកំពុងក្លាយជាបញ្ហាមួយយ៉ាងសំខាន់នៅកម្ពុជា ជាពិសេសចាប់ពីដើមឆ្នាំ ១៩៩០ ។ ដើម្បីចូលរួមចំណែកដោះស្រាយបញ្ហានេះ មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា កំពុងអនុវត្តនូវគំរោងមួយដែលមានឈ្មោះថា *"ភាពក្រខ្វក់ដោយថ្នាំពុលនៅតំបន់បឹងទន្លេសាប"* ។ គោលបំណង បង្កើនការយល់ដឹងដល់កសិករទាក់ទងការប្រើប្រាស់ថ្នាំពុល អោយមានលក្ខណៈសមស្រប ចូលរួមចំណែកក្នុងការជំរុញវិធានការចំរុះការពារដំណាំ ឬប្រពន្ធ័ប្រពលវប្បកម្មចំរុះ និងការពារសុខភាពសាធារណៈ តាមរយៈការបង្កើនការយល់ដឹងពីភាពគ្រោះថ្នាក់នៃការប្រើប្រាស់ថ្នាំពុលមិនបានសមស្រប និងការបន្ថយការប្រើប្រាស់ថ្នាំពុលក្នុងពេលអនាគត ។

ដំណើរការរបស់គំរោងនេះមានរយៈពេល ២ ឆ្នាំ ដោយចាប់ពីខែសីហា ១៩៩៩ ដល់ សីហា ២០០១ នៅក្នុងខេត្ត ៦ ជុំវិញបឹងទន្លេសាប រួមមាន កណ្តាល កំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង សៀមរាប និងកំពង់ធំ ។ សកម្មភាពពីរសំខាន់ក្នុងគំរោងនេះ គឺ: ការសិក្សាស្រាវជ្រាវលើទីផ្សារ លើអ្នកប្រើប្រាស់ថ្នាំពុល និងករណីសិក្សាលើអ្នកពុលថ្នាំ និងការអប់រំកសិករពីថ្នាំពុលនិងបញ្ហារបស់វា និងបច្ចេកទេសដាំដុះ ដោយមិនអាស្រ័យនឹងថ្នាំពុល ។

កម្មវិធីនេះ ត្រូវបានទទួលការឧបត្ថម្ភថវិកា ពីអង្គការអុកស្វាមអាមេរិកកាំង ( Oxfam America )

ចេញផ្សាយដោយ : មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CEDAC)
ផ្ទះលេខ ០១ ផ្លូវ ២២៣/១៦២ សង្កាត់ផ្សារដេប៉ូ ១
ខណ្ឌទូលគោក រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ : ១១១៨
ទូរស័ព្ទ និងទូរសារ : (៨៥៥) ២៣_៨៨០ ៩១៦
E-mail: Cedac@camnet.com.kh
បោះពុម្ពដោយ : រោងពុម្ពឥន្ទ្រីយ៍មាស